**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ក្រុមប្រឹក្សាធម្មនុញ្ញ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ៖ **ក. ឡេង រក្សា**
**ខ. ស៊ាន គឹមហេង**

សាស្ត្រាចារ្យណែនាំ
លោក **យូ តូនី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលរៀន ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

៚៙៛

នាងខ្ញុំឈ្មោះ **ឡេង ភក្រា** មានលោកឪពុកឈ្មោះ **ហៃ ម៉េងសុខ** អ្នកម្តាយឈ្មោះ **សិត សុវណ្ណារី** លោកតាឈ្មោះ **នង ឈន** និង លោកយាយឈ្មោះ **គិត ឡា** ខ្ញុំបាទឈ្មោះ **ស៊ាន គឹមហេង** មានលោកឪពុកឈ្មោះ **ស៊ាន សុខ** អ្នកម្តាយឈ្មោះ **យស់ ឆៃគាង** យើងខ្ញុំ ជានិស្សិតឆ្នាំទី៤ ជំនាន់ទី១៩ ផ្នែកនីតិសាស្ត្រ។ យើងខ្ញុំសូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតចំពោះលោកអ្នកមានគុណ ជាទីស្រលាញ់នៃកូនចៅ ដែលបានខិតខំប្រឹងប្រែងតស៊ូដោយព្រហ្មវិហារធម៌ចិញ្ចឹមបីបាច់ថែរក្សា ប្រកបដោយលះបង់អស់នូវកម្លាំងកាយចិត្ត លះបង់ទ្រព្យធនធាន និងផ្តល់នូវសេចក្តីស្រលាញ់ភាពកក់ក្តៅគ្រប់បែបយ៉ាង ដើម្បីអប់រំប្រៀនប្រដៅកូនចៅឲ្យខិតខំសិក្សារៀនសូត្រ បណ្តុះទឹកចិត្តឲ្យប្រកាន់ខ្ជាប់នូវកតញ្ញូតាធម៌ចំពោះគ្រប់អ្នកមានគុណ សេចក្តីអង់អាចក្លាហាន និងហ៊ានពុះពារជម្នះគ្រប់ឧបសគ្គក្នុងជីវិត នឹងក្លាយជាពលរដ្ឋល្អ សិស្សល្អ និងជាកូនល្អនៅក្នុងសង្គមជាតិយើង។ ទឹកចិត្តដល់ធំធេងដែលមិនអាចកាត់ថ្លៃបាន ដោយការយកចិត្តទុកដាក់ និងខិតខំរបស់លោកអ្នកមានគុណ ដើម្បីឱ្យរូបកូនបានបន្តការសិក្សាចាប់តាំងតែពីរូបកូននៅជាកុមារភាពមិនអាចសូម្បីតែសរសេរអក្សរបានរហូតដល់រូបកូនបានបន្តការសិក្សាដល់មហាវិទ្យាល័យទើបរូបកូនមានថ្ងៃនេះ គឺជាថ្ងៃដែលរូបកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ គឺសុទ្ធតែកើតចេញកម្លាំងពីញើសឈាមរបស់លោកអ្នកមានគុណ។

ទន្ទឹមនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅ ចំពោះ **ឯកឧត្តម បណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការ គណៈគ្រប់គ្រង និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង និងបង្រៀនដល់សិស្សនិស្សិតទាំងអស់ដោយសេចក្តីស្រលាញ់ពេញចិត្ត។

ជាងនេះទៅទៀតយើងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **យូ តូនី** ដែលជាសាស្ត្រាចារ្យណែនាំដល់រូបយើងខ្ញុំទាំងពីរ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយបង្ហាត់បង្ហាញណែនាំ កែតម្រូវ ផ្តល់អនុសាសន៍ល្អៗ និងជំរុញទឹកចិត្ត យើងខ្ញុំដើម្បីឱ្យកិច្ចការស្រាវជ្រាវនេះទទួលបាននូវភាពជោគជ័យ។

ជាចុងបញ្ចប់នេះ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធក្នុងលោកទាំងអស់ តាមជួយថែរក្សាការពារ ប្រសិទ្ធពរជ័យ សេចក្តីសុខចម្រើនជូនដល់អស់លោកទាំងអស់ ឱ្យមានសុខភាពល្អ កម្លាំងមាំមួន អាយុយឺនយូរ ទទួលជោគជ័យគ្រប់ភារកិច្ច និងរាល់សេចក្តីប៉ងប្រាថ្នា ជាពិសេសសូមជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

បន្ទាប់ពីបានទទួលការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំទៅលើមុខវិជ្ជាជាច្រើនរួចមកយើងបានទទួលចំណេះដឹងយ៉ាងទូលំទូលាយពីមុខវិជ្ជាទាំងនោះ ក្រោមការជួយខិតខំប្រឹងប្រែងរបស់ លោក លោកស្រីសាស្ត្រាចារ្យ ដែលបានខិតខំយកចិត្តទុកដាក់បង្រៀនដល់រូបយើងខ្ញុំ។ ដោយមានការណែនាំជ្រោមជ្រែង និងយកចិត្តទុកដាក់ខ្ពស់ដល់ការបង្ហាត់បង្ហាញក្នុងការបង្រៀនអស់ពីកម្លាំងកាយចិត្តទាំងនេះហើយ ទើបធ្វើឱ្យយើងខ្ញុំឈានមកដល់ការចងក្រងសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះឡើង ដើម្បីជាប្រយោជន៍ទូទៅក្នុងសង្គម និងការសិក្សាស្រាវជ្រាវ។

ក្នុងការសរសេរសារណាបញ្ចាប់ការសិក្សានេះឡើង យើងខ្ញុំបានជ្រើសរើសយកប្រធានបទមួយដែលទាក់ទងទៅនឹងស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជាដែលមានចំណងជើងថា "**ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**"។ ការជ្រើសរើសយកប្រធានបទនេះគឺដើម្បីឱ្យសិស្ស និស្សិត ជាពិសេសមជ្ឈដ្ឋានអ្នកស្រាវជ្រាវទូទៅ ដែលមានបំណងចង់សិក្សាពីស្ថាប័នកំពូលមួយនេះដែលជាស្ថាប័នបកស្រាយច្បាប់ ធម្មនុញ្ញភាពនៃច្បាប់ និងជាស្ថាប័នដែលដោះស្រាយវិវាទបោះឆ្នោតតំណាងរាស្ត្រ រដ្ឋសភា ព្រឹទ្ធសភា និងប្រព័ន្ធបោះឆ្នោតជាដើម ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណានេះនឹងអាចជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត មជ្ឈដ្ឋានអ្នកសិក្សាទូទៅនិងក៏ដូចជាប្រជាពលរដ្ឋគ្រប់រូបដែលមានបំណងចង់ស្វែងយល់បន្ថែមទៅលើស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលហៅកាត់ថា ក.ម.ធ នេះបានផងដែរ។ ម្យ៉ាងសារណានេះក៏ទុកជាស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីបានសិក្សាបន្ថែមឱ្យបានកាន់តែច្បាស់អំពីស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមួយនេះ។

ជាការពិតណាស់ ការសរសេរចងក្រងជៀសមិនផុតពីកំហុសអចេតនា និងចំណុចខ្វះខាតមួយចំនួនកើតឡើងជាក់ជាមិនខាន ដូចជាពាក្យពេចន៍ ខ្លឹមសារ អត្ថន័យ និងអក្ខរាវិរុទ្ធជាដើម។ យើងខ្ញុំសូមទទួលស្វាគមន៍ជានិច្ច នូវរាល់មតិរិះគន់កែលម្អក្នុងន័យស្ថាបនាជាមួយគំនិតល្អៗ របស់មិត្តអ្នកអានទាំងអស់ ក្នុងគោលបំណងឱ្យកាន់តែមានភាពល្អប្រសើរជាងមុន៕

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ការរៀបចំក្រុមប្រឹក្សាធម្មនុញ្ញ

**១.១. ខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** ........ ៣

១.១.១. សមាសភាព នៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ........ ៣

១.១.២. ភារកិច្ច នៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ........ ៤

១.១.៣. ការគ្រប់គ្រងប្រាក់បំណាច់នៃមន្ត្រីខុទ្ទកាល័យ ........ ៥

១.១.៤. ការរៀបចំបែងចែកភារកិច្ច នៃនាយកខុទ្ទកាល័យ ........ ៦

១.១.៥. មន្ត្រីក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា នៃខុទ្ទកាល័យ ........ ៧

**១.២. រចនាសម្ព័ន្ធអគ្គលេខាធិដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ** ........ ៨

១.២.១.អគ្គនាយកដ្ឋានរដ្ឋបាល~ហិរញ្ញកិច្ច ........ ៨

១.២.២. នាយកដ្ឋានរដ្ឋបាល ........ ៨

១.២.២.១. ការិយាល័យរដ្ឋបាល ........ ៨

១.២.២.២. ការិយាល័យទំនាក់ទំនងខាងក្រៅ និងពិធីការ ........ ៩

១.២.២.៣.នាយកដ្ឋានហិរញ្ញកិច្ច និងបុគ្គលិក ........ ១០

១.២.៣ អគ្គនាយកដ្ឋានសេវាច្បាប់ និងបច្ចេកទេស ........ ១២

១.២.៣.១. នាយកដ្ឋានសេវាច្បាប់ និងបច្ចេកទេស ........ ១៣

១.២.៣.២. នាយកដ្ឋានព័ត៌មានវិទ្យា និងបកប្រែភាសា ........ ១៤

១.២.៣.៣. នាយកដ្ឋានស្រាវជ្រាវ តម្កល់ឯកសារ និងបណ្ណាល័យ ........ ១៥

១.២.៤. នាយកដ្ឋានសវនកម្មផ្ទៃក្នុង ........ ១៧

**១.៣.ការជ្រើសតាំងសមាជិក ការដាក់ពិន័យ និងការដកពីដំណែង** ........ ១៧

១.៣.១. ការតែងតាំង និងជ្រើសតាំង ........ ១៧

១.៣.២. ការដាក់ពិន័យ ការដកពីតំណែង ........ ២០

## ជំពូកទី២

## ការពិនិត្យធម្មនុញ្ញភាព

**២.១.ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់** ........ ២៤

២.១.១ ការពិនិត្យជាអាទិកាល ........ ២៤

២.១.២ ការពិនិត្យជាបច្ឆាកាល ........ ២៤

**២.២. អំពីការប្តឹង** ........ ២៦

២.២.១ គោលការណ៍ទូទៅ ........ ២៦

២.២.២.អ្នកណាខ្លះអាចស្នើសុំ/ប្តឹងបាន ........ ២៦

**២.៣.ដំណើរការនៃសំណុំរឿងនៅនាយកដ្ឋានជំនាញ** ........ ៣០

២.៣.១. នីតិវិធិដែលត្រូវអនុវត្ត ........ ៣១

២.៣.១.១. ការចាត់តាំងសមាជិករាយការណ៍ ........ ៣១

២.៣.១.២. ភារកិច្ចរបស់សមាជិករាយការណ៍ ........ ៣២

## ជំពូកទី៣

## សមត្ថកិច្ចនានារបស់ក្រុមប្រឹក្សាធម្មនុញ្ញ

**៣.១.សមត្ថកិច្ចបកស្រាយច្បាប់** ........ ៣៣

៣.១.១នីតិវិធីក្នុងការបកស្រាយច្បាប់ ........ ៣៣

៣.១.២ សេចក្តីសម្រេចក្នុងការបកស្រាយច្បាប់ ........ ៣៤

**៣.២. សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត** ........ ៣៤

៣.២.១.សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ........ ៣៥

៣.២.២.សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា . ៣៨

**សេចក្តីសន្និដ្ឋាន** ........ ៤១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

កន្លងជាយូរណាស់មកហើយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា បានឆ្លងកាត់សង្គ្រាមវិនាសកម្មជាច្រើនដែលបានបណ្តាលឲ្យប្រទេសជាតិស្ទើរក្លាយជាផេះផង់ ធនធានមនុស្សត្រូវបានបាត់បង់ រីឯច្បាប់នៅក្នុងប្រទេសក៏ត្រូវបានផ្លាស់ប្តូរជាច្រើនទៅតាមរបបនយោបាយនីមួយៗផងដែរ។ រហូតមកដល់ឆ្នាំ ១៩៩៣ដែលកម្ពុជាបញ្ចប់សង្គ្រាមស៊ីវិលជាបឋមព្រះរាជាណាចក្រកម្ពុជាក៏បានបង្កើតនូវរដ្ឋធម្មនុញ្ញថ្មីមួយទៀតផងដែរ ដែលជាច្បាប់កំពូលនៃប្រទេសជាតិ។ រដ្ឋធម្មនុញ្ញនេះបានបង្កើតឲ្យមានស្ថាប័នកំពូលៗជាច្រើន ក្នុងការដឹកនាំនាវាកម្ពុជាឲ្យឆ្ពោះទៅរកភាពរីកចម្រើន។

ក្នុងនោះក៏មាន នូវស្ថាប័នកំពូល និងសំខាន់មួយគឺ ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នកំពូលមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដែលមានសមត្ថកិច្ចសម្រាប់ការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ និង សមត្ថកិច្ចចម្បងមួយទៀតរបស់ក្រុមប្រឹក្សាធម្មនុញ្ញនោះ គឺដោះស្រាយអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាការចូលរួមសំខាន់ផងដែរ ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា។

ក្រោយពីចាប់ដំណើការពេញលក្ខណៈនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៩៨ មកទល់ពេលបច្ចុប្បន្នក្រុមប្រឹក្សាធម្មនុញ្ញ បានបំពេញការងារជាច្រើនក្នុងការធានាការពារការគោរពរដ្ឋធម្មនុញ្ញបកស្រាយច្បាប់ដោះស្រាយ វិវាទទាក់ទិននឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអ្វីដែលមានចែងពីសមត្ថកិច្ចរបស់ស្ថាប័ននេះដោយរដ្ឋធម្មនុញ្ញរបស់ ព្រះរាជាណាចក្រកម្ពុជា។ សមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញមានប្រធាន ១ រូប និងសមាជិកចំនួន ៨រូប ។ ប្រធានត្រូវបានជ្រើសតាំងតាមការបោះឆ្នោត ដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាត រៀងរាល់បីឆ្នាំម្តងក្រោយពីសមាជិកថ្មី ៣រូបចូលកាន់តំណែង ប្រធានមានឋានៈ និងបុព្វសិទ្ធិស្មើ នឹងប្រធានរដ្ឋសភាសមាជិកមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា។ ជាធម្មតាអាណត្តិរបស់សមាជិកគឺ ៩ឆ្នាំ ប៉ុន្តែសមាជិកចំនួន ៣រូប ត្រូវបានជ្រើសតាំង ឬតែងតាំងរាល់បីឆ្នាំម្តង ក្នុងអាណត្តិទី១ ត្រូវបានតែងតាំង ឬជ្រើសតាំងសមាជិក ៣រូបសម្រាប់បីឆ្នាំ ៣រូប សម្រាប់ប្រាំមួយឆ្នាំ និង ៣រូប សម្រាប់ប្រាំបួនឆ្នាំ។ សមាជិក៣រូប តែងតាំងដោយព្រះមហាក្សត្រ ៣រូប ជ្រើសតាំងដោយរដ្ឋសភា និង ៣រូបទៀត ជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ សមាជិកទាំងអស់ត្រូវបានតែងតាំង ឬជ្រើសតាំងពីចំណោមឥស្សរជន ដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ឆ្នាំ មាន

បទពិសោធន៍ការងារ យ៉ាងតិច ១៥ឆ្នាំ និង មានសញ្ញាបត្រឧត្តមសិក្សាឡើងទៅ ក្នុងវិស័យច្បាប់ រដ្ឋបាល ការទូត និង សេដ្ឋកិច្ច ។

ជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយ មកពិនិត្យដោយខ្លួនឯងបានឡើយ ។ មានតែព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន និងតំណាងរាស្ត្រមួយភាគដប់ ឬតុលាការប៉ុណ្ណោះ ដែលអាចសុំទៅក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាន ។ ប្រជារាស្ត្រ និងគណបក្សនយោបាយអាចលើកសំណើ ឬ ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមលក្ខខណ្ឌ ដែលមានចែង។

ដើម្បីឲ្យមានការងាយស្រួលយល់អំពីស្ថាប័ន ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាស្របតាមការរីកចម្រើន និងការវិវត្តរបស់សង្គមជាតិយើងជាអ្នកសិក្សាត្រូវតែយល់ដឹងឲ្យបានច្បាស់លាស់ពីស្ថាប័នកំពូលមួយនេះ ៖

តើអ្វីទៅជាស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា?

តើមាន ការិយាល័យ រចនាសម្ព័ន្ធ សមាសភាពសមាជិក និងសមត្ថកិច្ចរបស់ស្ថាប័ននេះមានអ្វីខ្លះ?

យើងខ្ញុំបានធ្វើការចងក្រងលម្អិតបញ្ជាក់ នៅក្នុងអត្ថបទទៅតាមផ្នែកនីមួយៗ។

# ជំពូកទី១. ការរៀបចំក្រុមប្រឹក្សាជម្ងនុញ្ញ

# ជំពូកទី១. ការរៀបចំក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នកំពូលមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ សម្រាប់ការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ព្រមទាំងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើស តាំងសមាជិកព្រឹទ្ធសភា ។ ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នកំពូលមួយដែលឯករាជ្យ និងអព្យាក្រឹត្យមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ ច្បាប់រៀបចំអង្គការមួយនឹងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញបានចាប់ដំណើរការពេញលក្ខណៈក្នុងការបំពេញសកម្មភាពរបស់ខ្លួន នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ ដែលជាលើកទីមួយក្នុងប្រវត្តិសាស្ត្រនៃកម្ពុជា។ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៤៩៨/ ០៦ ចុះនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ ១៩៩៨។

ការបង្កើតស្ថាប័ននេះឡើង គឺដើម្បីរួមចំណែកក្នុងករណីក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ការកសាងនីតិរដ្ឋ និងការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ាហើយមានអានុភាពទៅលើគ្រប់អំណាចទាំងអស់ ដែលចែងក្នុងរដ្ឋធម្មនុញ្ញហើយត្រូវចុះក្នុងរាជកិច្ច។

## ១.១. ខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

យោងទៅតាមសេចក្តីសម្រេច ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបង្កើតខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គភាពមួយដោយដាច់ឡែក មិនស្ថិតក្នុងរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ និងត្រូវស្ថិតក្រោមឱវាទផ្ទាល់របស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។[1]

### ១.១.១. សមាសភាព នៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានសមាសភាព ១២រូប និងមានមុខតំណែងដូចខាងក្រោម៖

(1). ប្រការ១ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

- នាយកខុទ្ទកាល័យ ចំនួន ១ រូប
- នាយករងខុទ្ទកាល័យ ចំនួន ៣ រូប
- បេសកជនទីប្រឹក្សាបច្ចេកទេស ចំនួន ២ រូប
- អនុពន្ធសភា ចំនួន ១ រូប
- អនុពន្ធ គ.ជ.ប ចំនួន ១ រូប
- ជំនួយការ ចំនួន ២ រូប
- លេខាធិការ ចំនួន ២ រូប

នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ បេសកជនទីប្រឹក្សាបច្ចេកទេស អនុពន្ធសភា និង អនុពន្ធសភា គ.ជ.ប ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមការក្រាបបង្គំស្នើសុំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ ជំនួយការ និង លេខាធិការ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ ការកែសម្រួលមុខតំណែង និងចំនួនមន្ត្រីខុទ្ទកាល័យខាងលើ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ ខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានថវិកាសម្រាប់ដំណើរការការងាររបស់ខ្លួន ក្នុងកញ្ចប់ថវិការបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ។[2]

### ១.១.២. ភារកិច្ច នៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានភារកិច្ចជាអាទ៍ះ

- ទទួលការងារធ្វើទំនាក់ទំនងជាមួយខុទ្ទកាល័យរបស់ថ្នាក់ដឹកនាំនៃស្ថាប័នជាតិផ្សេងទៀត
- ជួយការងារប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះកិច្ចការទូទៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លើសំណុំរឿងទាំងឡាយ ដែលប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានប្រគល់ឱ្យពិនិត្យ
- ផ្សព្វផ្សាយព័ត៌មាន និងការងារផ្សេងទៀត ដែលដាក់ចេញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
- រៀបចំកាលវិភាគរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ព្រមទាំងសម្របសម្រួលការអនុវត្តការងារឱ្យសមស្របតាមកាលវិភាគដែលបានកំណត់

(2) .ប្រការ២ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

- សម្របសម្រួលសកម្មភាពការងារផ្សេងៗជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ
- តាមដានការអនុវត្តបញ្ជារបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានដាក់ចេញក្នុងដែនសមត្ថកិច្ចនីមួយៗ
- បំពេញការងារផ្សេងៗទៀត តាមការណែនាំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

### **១.១.៣. ការគ្រប់គ្រងប្រាក់បំណាច់នៃមន្ត្រីខុទ្ទកាល័យ**

នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ បេសកជនទីប្រឹក្សាបច្ចេកទេស អនុពន្ធសភា អនុពន្ធ គ.ជ.ប ជំនួយការ និងលេខាធិការនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលប្រាក់បំណាច់ប្រចាំខែ តាមកម្រិតដូចខាងក្រោម តាមសេចក្តីសម្រេចថ្មី ស្តីពីការប្រាក់បំណាច់ប្រចាំខែនេះ ៖

| ល.រ | កម្រិតមុខតំណែង | ឈ្មោះមុខតំណែង | ប្រាក់បំណាច់ ប្រចាំខែ (រៀល) |
|---|---|---|---|
| ១ | កម្រិតទី១ | នាយកខុទ្ទកាល័យ | ៣ ៥០០ ០០០ |
| ២ | កម្រិតទី២ | នាយករងខុទ្ទកាល័យ | ២ ៨០០ ០០០ |
| ៣ | កម្រិតទី៣ | បេសកជនទីប្រឹក្សាបច្ចេកទេស | ២ ១០០ ០០០ |
| ៤ | កម្រិតទី៤ | អនុពន្ធសភា/អនុពន្ធ គ.ជ.ប | ១ ៥០០ ០០០ |
| ៥ | កម្រិតទី៥ | ជំនួយការ | ១ ១០០ ០០០ |
| ៦ | កម្រិតទី៦ | លេខាធិការ | ១ ០០០ ០០០ |

*ដកស្រង់ពី សេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

មន្ត្រីខុទ្ទកាល័យគ្រប់កំរិត អាចជ្រើសរើសប្រាក់បំណាច់តាមការកំណត់ក្នុងសេចក្តីសម្រេចនេះ ឬប្រាក់បំណាច់មុខងារផ្សេងបានតែមួយ ក្នុងករណីមន្ត្រីខុទ្ទកាល័យមានក្របខណ្ឌក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ឬ ក្របខណ្ឌផ្សេងទៀត។[3]

នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ និងមន្ត្រីគ្រប់កម្រិតក្នុងខុទ្ទកាល័យ ត្រូវទទួលបានប្រាក់ឧបត្ថម្ភ និង របបលាភការផ្សេងៗទៀត ព្រមទាំងត្រូវទទួលបានប្រាក់បេសកកម្មនៅក្នុង

([3]). ប្រការ៥ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

និងក្រៅប្រទេស តាមសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ និងមន្ត្រីគ្រប់កំរិតក្នុងខុទ្ទកាល័យ ត្រូវបានទទួលការវាយតម្លៃលើសកម្មភាពការងារ ក្នុងរយៈពេល ១( មួយ ) ឆ្នាំម្តង ដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីទទួលបានមេដាយ ឬ គ្រឿងឥស្សរិយយស តាមកម្រិតគុណបំណាច់របស់ខ្លួន។[4]

### ១.១.៤. ការរៀបចំបែងចែកភារកិច្ច នៃនាយកខុទ្ទកាល័យ

នាយកខុទ្ទកាល័យ ត្រូវរៀបចំបែងចែកភារកិច្ចនាយករងខុទ្ទកាល័យ និងមន្ត្រីគ្រប់កម្រិតក្នុងខុទ្ទកាល័យដើម្បីធានាការអនុវត្តភារកិច្ចរបស់ខុទ្ទកាល័យឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយមានការឯកភាពពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានដូចជា[5]៖

- មន្ត្រីគ្រប់កម្រិតបំពេញភារកិច្ចក្នុងមុខតំណែង ដូចមានកំណត់ក្នុងប្រការ២នៃសេចក្តីសម្រេចនេះ អាចត្រូវបានបញ្ចប់មុខតំណែងរបស់ខ្លួន តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។
- មន្ត្រីខុទ្ទកាល័យត្រូវបានបញ្ចប់មុខតំណែងរបស់ខ្លួន នៅពេលមានការបញ្ចប់មុខងារ និងតួនាទីរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។
- មន្ត្រីខុទ្ទកាល័យ ដែលពីមុនមិនមែនជាមន្ត្រីក្នុងក្របខណ្ឌ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ពុំអាចទាមទារក្របខណ្ឌ ក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ នៅពេលបញ្ចប់មុខតំណែងរបស់ខ្លួនក្នុងខុទ្ទកាល័យ ដោយផ្អែកទៅលើការតែងតាំងខ្លួនជាមន្ត្រីខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញនោះឡើយ ។[6]
- មន្ត្រីខុទ្ទកាល័យ ដែលមានក្របខណ្ឌក្នុងអគ្គលេខាធិកាដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ឬ ក្របខណ្ឌផ្សេងទៀត បានទទួលការតែងតាំងក្នុងកម្រិតមុខតំណែងណាមួយក្នុងខុទ្ទកាល័យត្រូវដាក់ឱ្យស្ថិតនៅក្របខណ្ឌដើម ។ ក្នុងពេលបំពេញការងារនៅក្នុងខុទ្ទកាល័យ មន្ត្រីក្របខណ្ឌក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ឬ ក្របខណ្ឌផ្សេងទៀត ត្រូវបានដំឡើងថ្នាក់/ឬឋានន្តរស័ក្តិដោយស្វ័យប្រវត្តិ នៅថ្ងៃទី ១៣ ខែ

(4). ប្រការ៦ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

(5). ប្រការ៧ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

(6). ប្រការ៨ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

មេសា នៃឆ្នាំនីមួយៗ ដោយផ្អែកលើអតីតភាពការងារ ២( ពីរ ) ឆ្នាំ ព្រមទាំងត្រូវបានគិតអតីតភាព សម្រាប់ទទួលសោធននិវត្តន៍។[7]

ក្រោយពេលបញ្ចប់ពីមុខតំណែងមន្ត្រី ខុទ្ទកាល័យដែលមានក្របខណ្ឌក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានដាក់ពាក្យសុំចូលបម្រើការងារក្នុងក្របខណ្ឌដើមវិញ ដោយត្រូវបានផ្តល់ជូនជាស្វ័យប្រវត្តិនូវឋានន្តរស័ក្តិថ្នាក់ ដោយអនុលោមតាមខ្លឹមសារនៃប្រការ៩ ព្រមទាំងប្រាក់បំណាច់មុខងារ ផ្អែកលើមុខដំណែង ដែលមានមុនពេលតែងតាំងចូលបម្រើការងារនៅក្នុងខុទ្ទកាល័យ ។ មន្ត្រីសាមី និងទទួលបានសិទ្ធអាទិភាពក្នុងការតែងតាំងមុខតំណែងដើម ឬមុខតំណែងទំនេរផ្សេងទៀត ផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។ចំពោះមន្ត្រីខុទ្ទកាល័យ ដែលជាមន្ត្រីរាជការក្នុងក្របខណ្ឌផ្សេងទៀត ក្រោយពេលបញ្ចប់ពីមុខតំណែង ត្រូវដាក់ពាក្យសុំចូលបម្រើការងារនៅស្ថាប័នសាមីវិញ ស្របក្នុងលក្ខខណ្ឌរបស់ស្ថាប័នសាមីនោះ។[8]

### ១.១.៥. មន្ត្រីក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា នៃខុទ្ទកាល័យ

ក្រៅពីការប្រើប្រាស់មន្ត្រីក្នុងតំណែងដែលមានកំណត់នៅក្នុងប្រការ២ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ ខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញអាចស្នើសុំអគ្គលេខាធិកាដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញផ្តល់មន្ត្រីក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យារបស់អគ្គលេខាធិការដ្ឋាន ដើម្បីរ៉ាប់រងលើកិច្ចការផ្គត់ផ្គង់ និង រដ្ឋបាល។

- ❖ មន្ត្រីពិធីការ
- ❖ អ្នកបើកបរ
- ❖ លេខាធិការការិយាល័យ
- ❖ ការីកុំព្យូទ័
- ❖ អ្នកបកប្រែភាសា
- ❖ មន្ត្រីជំនាញផ្សេងទៀតដែលជាតម្រូវការនៃភារកិច្ចរបស់ខុទ្ទកាល័យ។[9]

ទីប្រឹក្សា និង ជំនួយការ របស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលទទួលបានការតែងតាំងដោយព្រះរាជក្រឹត្យ ឬ ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ តាមបទបញ្ញត្តិនៃប្រការ៧ថ្មី

(7).ប្រការ៩ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

(8).ប្រការ១០ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

(9).ប្រការ១១ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

នៃសេចក្តីសម្រេចលេខ ២៨/២០០៨ កបធ.សសរ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្មសេចក្តីសម្រេចស្តីពីរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម និងរបបបេសកកម្មរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវរក្សាទុកដែលរហូតមានការតែងតាំងថ្មី ដែលអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃសេចក្តីសម្រេចនេះ ។ ក្រោយការតែងតាំងសមាសភាពខុទ្ទកាល័យរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្របតាមបទបញ្ញត្តិដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេច ទីប្រឹក្សាចំនួន ០៥រូប និងជំនួយការចំនួន ០៣រូប របស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានក្នុងប្រការ៧ថ្មី នៃសេចក្តីសម្រេច ត្រូវទុកជានិរាករណ៍។[10]

## ១.២. រចនាសម្ព័ន្ធអគ្គលេខាធិដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួនជួយក្នុងការងារនៅក្រោមការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ ។

អគ្គលេខាធិការគ្រប់គ្រង និង ចាត់ចែងការងាររដ្ឋបាលទាំងឡាយរបស់ក្រុមប្រឹក្សា ក្រោមការណែនាំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

អគ្គលេខាធិការអាចទទួលសិទ្ធិពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចុះហត្ថលេខាលើលិខិត ឬសេចក្តីសម្រេចរដ្ឋបាល ។

### ១.២.១.អគ្គនាយកដ្ឋានរដ្ឋបាល~ហិរញ្ញកិច្ច

អគ្គនាយកដ្ឋានរដ្ឋបាល~ហិរញ្ញកិច្ចស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន។ អគ្គនាយកដ្ឋាននេះមានការសម្រេចភារកិច្ចទាំងឡាយជូនអគ្គលេខាធិការដ្ឋាន ។

### ១.២.២. នាយកដ្ឋានរដ្ឋបាល

#### ១.២.២.១. ការិយាល័យរដ្ឋបាល

ការិយាល័យរដ្ឋបាលស្ថិតនៅក្រោមឱវាទប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។ ការិយាល័យនេះមានមុខងារដូចតទៅ ៖

---

([10]).ប្រការ១២ នៃសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

- ទទួលលិខិត ចុះសៀវភៅចូលធ្វើកំណត់បង្ហាញតាមឋានានុក្រម ធ្វើការបែងចែកលិខិតតាមចំណាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

- រៀបចំលិខិតរដ្ឋបាលដាក់ជូនថ្នាក់ដឹកនាំអគ្គលេខាធិដ្ឋាន

- ចុះលិខិតចេញ និងបញ្ជូនលិខិតទៅកាន់គោលដៅ

- ទុកដាក់ត្រាអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ និងរក្សាទុកឯកសាររដ្ឋបាលឲ្យបានត្រឹមត្រូវ និងប្រគល់ជូននាយកដ្ឋានស្រាវជ្រាវ តម្កល់ឯកសារ និងបណ្ណាល័យតាមពេលវេលាកំណត់

- គ្រប់គ្រងថែទាំរាល់បណ្តាញអគ្គិសនី ទឹកស្អាត ទឹកកខ្វក់ ម៉ាស៊ីនត្រជាក់ ទូទឹកកក កង្ហារ ទូរទស្សន៍ អំភ្លី មេក្រូ ទូរសព្ទ័ និងសម្ភារឧបករណ៍ប្រើប្រាស់ផ្សេងៗរបស់ស្ថាប័ន

- គ្រប់គ្រង ធានាការពារ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ ទាំងក្នុង និងក្រៅស្ថាប័ន ដោយសហការជាមួយនគរបាលយាមស្ថាប័ន នៅរាល់ពេលប្រជុំ ទទួលភ្ញៀវ សន្និបាត សន្និសិទ និងសវនាការ

- គ្រប់គ្រងការងារបម្រើថ្នាក់ដឹកនាំក្រុមប្រឹក្សាធម្មនុញ្ញ និងអគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ការធ្វើអនាម័យបន្ទប់ធ្វើការ និងក្នុងបរិវេណក្រុមប្រឹក្សាធម្មនុញ្ញ

- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញប្រចាំខែ ឆ្នាំ និង អាណត្តិ

- អនុវត្តការងារផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

### ១.២.២.២. ការិយាល័យទំនាក់ទំនងខាងក្រៅ និងពិធីការ

ការិយាល័យទំនាក់ទំនងខាងក្រៅ និងពិធីការស្ថិតក្រោមឱវាទប្រធានការិយាល័យមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។ ការិយាល័យនេះមានមុខងារដូចតទៅ ៖

- ធ្វើទំនាក់ទំនងខាងក្រៅជាមួយស្ថាប័ន ក្រសួង អង្គភាពរដ្ឋ អង្គការជាតិ និងអន្តរជាតិពាក់ព័ន្ធ ទាំងក្នុង និងក្រៅប្រទេស
- ត្រៀមទទួលភ្ញៀវជាតិ និងបរទេស មកទំនាក់ទំនង ឬ ជួបថ្នាក់ដឹកនាំ
- ចាត់ចែងទទួលនិងជូនដំណើរគណៈប្រតិភូជាតិ និងអន្តរជាតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

- រៀបចំកន្លែងប្រជុំ សន្និបាត សន្និសិទ ការទទួលភ្ញៀវជាតិ និងភ្ញៀវបរទេស
- រៀបចំចាត់ចែង បញ្ជូនប័ណ្ណជូនពរ លិខិតថ្លែងអំណរគុណ និងសាររំលែកទុក្ខរបស់ថ្នាក់ដឹកនាំ
- រៀបចំបែបបទសុំលិខិតឆ្លងដែន និងទិដ្ឋាការជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ
- រៀបចំបែបបទសុំច្បាប់អនុញ្ញាតពីអាជ្ញាធរកាសចរស៊ីវិលសម្រាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងភ្ញៀវអន្តរជាតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលត្រូវចូលបន្ទប់ VIP
- តុបតែងលម្អស្ថាប័នពេលបុណ្យជាតិ និងបុណ្យប្រពៃណីជាតិ
- បកប្រែជូនថ្នាក់ដឹកនាំ និង កត់ត្រាធ្វើរបាយការណ៍ពេលជួបភ្ញៀវ
- រក្សាទុកដាក់ឯកសារពាក់ព័ន្ធឲ្យបានល្អ មានរបៀបរៀបរយ
- បំពេញភារកិច្ចជាពិធីករពេលមានពិធីផ្សេងៗ
- អនុវត្តការងារផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

### ១.២.២.៣. នាយកដ្ឋានហិរញ្ញកិច្ច និងបុគ្គលិក

នាយកដ្ឋានហិរញ្ញកិច្ច និងបុគ្គលិកស្ថិតនៅក្រោមឱវាទប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួនសមស្រប ។ នាយកដ្ឋាននេះមានការិយាល័យចំនួន២ នៅក្រោមឱវាទគឺ ៖

#### ក. ការិយាល័យគណនេយ្យ និងផ្គត់ផ្គង់

ការិយាល័យគណនេយ្យ និងផ្គត់ផ្គង់ស្ថិតនៅក្រោមឱវាទប្រធានការិយាល័យមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។

ការិយាល័យនេះមានមុខងារដូចតទៅ៖

- ⇨ កសាងផែនការយុទ្ធសាស្ត្រចំណាយថវិការរដ្ឋរយៈពេលមធ្យម និងផែនការចំណាយ
- ⇨ ថវិការដ្ឋប្រចាំឆ្នាំលើកម្មវិធីចំណាយប្រចាំត្រីមាស តាមដានការអនុវត្តចំណាយថវិការតាមគម្រោងផែនការ ដោយធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងសម្ភារប្រចាំខែជូនថ្នាក់ដឹកនាំស្ថាប័ន និងធ្វើរបាយការណ៍សម្រេចទូទាត់ចំណូលចំណាយថវិការដ្ឋប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។
- ⇨ ផ្តល់មតិយោបល់ក្នុងការលើកគម្រោងចំណាយថវិកា សម្ភារ និងប្រេងឥន្ធនៈ

- ⇨ គ្រប់គ្រង ថវិកា សម្ភារ និងប្រេងឥន្ធនៈ មធ្យោបាយធ្វើដំណើរ និងទ្រព្យសម្បត្តិអចលនវត្ថុ ទាំងរបស់ស្ថាប័នដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋាន និងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ⇨ ផ្គត់ផ្គង់ សម្ភារ និងថវិកា ដល់គ្រប់អង្គភាពតាមតម្រូវការជាក់ស្តែង និងតាមការសម្រេចរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងថ្នាក់ដឹកនាំស្ថាប័ន
- ⇨ ធ្វើរបាយការណ៍ស្តីពីឥណទានដែលបានអនុវត្តប្រចាំខែជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើរបាយការណ៍សាច់ប្រាក់ក្នុងបេឡាប្រចាំសប្តាហ៍
- ⇨ អនុវត្តការងារលទ្ធកម្មសាធារណៈក្នុងការទិញ ការជួសជុល ការសាងសង់ សមស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការសម្រេចរបស់ថ្នាក់ដឹកនាំស្ថាប័ន
- ⇨ ធានាការបើកប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ ឱ្យបានទៀងទាត់ ជូនសមាជិក
- ⇨ ក្រុមប្រឹក្សាធម្មនុញ្ញ មន្ត្រីរាជការ ទីប្រឹក្សា ជំនួយការ ភ្នាក់ងារជាតិជាប់កិច្ចសន្យា និងប្រាក់សោធនិវត្ត ជូននិវត្តជនរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- ⇨ គោរពច្បាប់ លិខិតបទដ្ឋាន សីលធម៌ និងការសម្ងាត់វិជ្ជាជីវៈគណនេយ្យឱ្យបានល្អ
- ⇨ អនុវត្តផែនការកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ⇨ អនុវត្តការងារផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

### ខ- ការិយាល័យបុគ្គលិក

ការិយាល័យបុគ្គលិកគឺស្ថិតនៅក្រោមឱវាទប្រធានការិយាល័យមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។ ការិយាល័យនេះមានមុខងារដូចតទៅ ៖

- ⇨ គ្រប់គ្រងនិងធ្វើបច្ចុប្បន្នភាពសំណុំលិខិតផ្ទាល់ខ្លួនរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ
- ⇨ គ្រប់គ្រង់ និងធ្វើបច្ចុប្បន្នភាពសំណុំលិខិតផ្ទាល់ខ្លួនរបស់អគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទីប្រឹក្សា ជំនួយការ និងភ្នាក់ងារជាតិជាប់កិច្ចសន្យា
- ⇨ ត្រួតពិនិត្យវត្តមាន និងសកម្មភាពការងាររបស់មន្ត្រីរាជការ និងភ្នាក់ងារជាតិជាប់កិច្ចសន្យា

- ⇨ រៀបចំសេចក្តីព្រាងលិខិតបទដ្ឋាននានាដូចជា សេចក្តីសម្រេច លិខិតបង្គាប់ការ លិខិតបញ្ជាបេសកកម្ម លិខិតឧទ្ទេសនាម សេចក្តីជូនដំណឹង វិញ្ញាបនប័ត្ររដ្ឋបាល លិខិតផ្ទេរសិទ្ធិ លិខិតអនុញ្ញាតច្បាប់ និងសំណើរផ្សេងៗ
- ⇨ ផ្តួចផ្តើមគំនិតធ្វើតារាងសម្រាប់ធ្វើសំណើរតឡើង ឋានន្តរស័ក្តិ ថ្នាក់ កម្រិតប្រាក់បំណាច់មុខងារ ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ គ្រឿងឥស្សរិយយស ដល់មន្ត្រីដែលធ្វើសកម្មភាពការងារ និង គ្រប់ក្របខ័ណ្ឌ
- ⇨ ធ្វើបច្ចុប្បន្នភាពតារាងបៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ
- ⇨ ធ្វើបច្ចុប្បន្នភាពតារាងប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ ទីប្រឹក្សាជំនួយការ និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា
- ⇨ ណែនាំមន្ត្រីក្នុងការិយាល័យឱ្យអនុវត្តច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់រដ្ឋ របស់ក្រុមប្រឹក្សាធម្មនុញ្ញ គោរពសីលធម៌ និងរក្សាការសម្ងាត់សម្រាប់វិជ្ជាជីវៈឱ្យបានល្អ
- ⇨ ធ្វើរបាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ ប្រចាំខែជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ⇨ កសាងផែនការបណ្តុះបណ្តាល និងតម្រូវការធនធានមនុស្ស
- ⇨ រៀបចំបែបបទ និងឯកសារផ្សេងៗក្នុងការប្រឡងជ្រើសរើសមន្ត្រីថ្មីឱ្យចូលបំរើការងារ និងការប្រឡងផ្ទៃក្នុងប្តូរក្របខណ្ឌ
- ⇨ រៀបចំបែបបទ និងនីតិវិធីសម្រាប់ស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ និងទីប្រឹក្សា ជំនួយការ និងភ្នាក់ងារជាប់កិច្ចសន្យា
- ⇨ រៀបចំធ្វើប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មន្ត្រីរាជការ ទីប្រឹក្សា ជំនួយការ និងភ្នាក់ងារជាតិជាប់កិច្ចសន្យា
- ⇨ អនុវត្តការងារផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

### ១.២.៣ អគ្គនាយកដ្ឋានសេវាច្បាប់ និងបច្ចេកទេស

អគ្គនាយកដ្ឋានសេវាច្បាប់ និងបច្ចេកទេសស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ។ អគ្គនាយកដ្ឋាននេះមានការទទួលខុសត្រូវចំពោះ

ថ្នាក់លើ និងថ្នាក់ក្រោមនូវរាល់កិច្ចការរបស់នាយកដ្ឋានក្រោមឱវាទក្នុងការសម្រេចភារកិច្ចទាំងឡាយជូនអគ្គលេខាធិការដ្ឋាន ។

**១.២.៣.១. នាយកដ្ឋានសេវាច្បាប់ និងបច្ចេកទេស**

នាយកដ្ឋានសេវាច្បាប់ និងបច្ចេកទេសស្ថិតនៅក្រោមការគ្រប់របស់អគ្គនាយកមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។ នាយកដ្ឋាននេះមានការិយាល័យចំនួន៣ ដែលស្ថិតនៅក្រោមឱវាទគឺ ការិយាល័យទី១ ការិយាល័យទី២ និងការិយាល័យទី៣ ។ ការិយាល័យនីមួយៗមានប្រធានការិយាល័យមួយរូប អមដោយអនុប្រធានមួយចំនួនសមស្រប និងមានភារកិច្ចដូចៗគ្នា ដោយអនុវត្តតាមការផ្លាស់វេនបន្តបន្ទាប់តាមរបៀបវិលជុំដែលមានមុខងារដូចតទៅ ៖

**ក. និតិវិធីនៃបណ្តឹង ឬ សំណើ**

- ទទួលពាក្យបណ្តឹង ឬ សំណើ និងចុះបញ្ជីក្នុងសៀវភៅទទួលសុំណុំរឿង និងទទួលលិខិតជូនជ្រាបពីស្ថាប័នពាក់ព័ន្ធ និងកត់ត្រាចូលក្នុងសៀវភៅលិខិតចូល
- ធ្វើកំណត់បង្ហាញរឿងជូនថ្នាក់ដឹកនាំ
- ធ្វើជាជំនួយការសមាជិករាយការណ៍របស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងការសិក្សាស្រាវជ្រាវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនិងបណ្តឹង ឬ សំណើ
- ចូលរួមធ្វើជាជំនួយការលេខាធិការកត់ត្រា និងធ្វើកំណត់ហេតុកិច្ចប្រជុំ ឬសវនការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- ជួយរៀបចំឯកសារ កម្មវិធីលម្អិត និងធ្វើជំនួយស្មារតីជូនថ្នាក់ដឹកនាំសម្រាប់កិច្ចប្រជុំ ឬ សវនការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- ធ្វើការស៊ើបអង្កេតលើបណ្តឹងទាក់ទងនឹងវិវាទកម្មនៃការបោះឆ្នោត តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ឬ ថ្នាក់ដឹកនាំក្រុមប្រឹក្សាធម្មនុញ្ញ

**ខ. ស្ថាប័នពាក់ព័ន្ធ ព្រឹទ្ធសភា រដ្ឋសភា គ.ជ.ប និង ស្ថាប័នផ្សេងទៀត**

- ស្រាវជ្រាវរកឯកសារទាំងឡាយរបស់ស្ថាប័នទាំងនោះដែលពាក់ព័ន្ធក្រុមប្រឹក្សាធម្មនុញ្ញ
- តាមដានសម័យប្រជុំ ។

**គ. ការផ្សព្វផ្សាយ ឬ សិក្ខាសាលារបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

- ធ្វើកំណត់ហេតុ ឬ របាយការណ៍ ។

**ឃ.សិក្សាស្រាវជ្រាវ និងការងារផ្សេងៗទៀតដែលថ្នាក់ដឹកនាំស្ថាប័នប្រគល់ ជូនរួមមាន**

- ច្បាប់
- លិខិតបទដ្ឋានគតិយុត្ត និងឯកសារដទៃទៀតរបស់ប្រទេសកម្ពុជា ឬ ប្រទេសផ្សេងទៀត ដើម្បីពង្រឹងសមត្ថភាពការងាររបស់មន្ត្រីនៃនាយកដ្ឋាន
- អនុវត្តការងារផ្សេងៗទៀតដែលថ្នាក់ដឹកនាំស្ថាប័នប្រគល់ជូន ។

**១.២.៣.២. នាយកដ្ឋានព័ត៌មានវិទ្យា និងបកប្រែភាសា**

នាយកដ្ឋានព័ត៌មានវិទ្យាស្ថិតនៅក្រោមឱវាទប្រធានការិយាល័យមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។ នាយកដ្ឋាននេះមានការិយាល័យចំនួន២ នៅក្រោមឱវាទ ៖

**ក. ការិយាល័យព័ត៌មានវិទ្យា**

ការិយាល័យព័ត៌មានវិទ្យាស្ថិតនៅក្រោមឱវាទប្រធានការិយាល័យមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។ ការិយាល័យនេះមានមុខងារដូចតទៅ ៖

- គ្រប់គ្រងប្រព័ន្ធ Internet និងជួយសម្រួលការប្រើប្រាស់ Internet របស់ស្ថាប័ន
- គ្រប់គ្រងបង្ហោះ Website និងការបញ្ចូលក្នុង Web page នូវរាល់ឯកសាររបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានសេចក្តីសម្រេច សេចក្តីជូនដំណឹង ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ សេចក្តីប្រកាសព័ត៌មាន បទបញ្ជាផ្ទៃក្នុង ។ល។
- ជួយសម្រួលការប្រើប្រាស់ ការជួសជុល ការថែរក្សាសម្ភារព័ត៌មានវិទ្យា និងឧបករណ៍ផលិតឯកសារគ្រប់ប្រភេទរបស់ស្ថាប័ន
- អនុវត្តតាមក្រមសីលធម៌ និងរក្សាការសម្ងាត់វិជ្ជាជីវៈ
- រៀបចំធ្វើខ្សែវីដេអូអំពីសកម្មភាពក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់ជាឯកសារក្នុងអាណត្តិនីមួយៗ
- ទទួលបន្ទុកថតរូបភាព ថតវីដេអូ ទុកដាក់ឧបករណ៍ ខ្សែអាត់រូបភាព ខ្សែអាត់សម្លេងពេលប្រជុំក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនិងការធ្វើកំណត់ហេតុ
- អនុវត្តការងារផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

**ខ. ការិយាល័យបកប្រែភាសា**

ការិយាល័យបកប្រែភាសាស្ថិតនៅក្រោមឱវាទប្រធានការិយាល័យមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។ ការិយាល័យនេះមានមុខងារដូចតទៅ ៖

- ❖ បកប្រែសេចក្តីសម្រេច និងសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ពីភាសាខ្មែរទៅភាសាបារាំង និង ភាសាអង់គ្លេស
- ❖ ចូលរួមជាជំនួយការលេខាធិការកត់ត្រាពេលប្រជុំក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនិងការបកប្រែ និងធ្វើកំណត់ហេតុកិច្ចប្រជុំ
- ❖ រៀបចំឯកសារសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនឹងការបកប្រែ
- ❖ ចូលរួមបកប្រែជូនថ្នាក់ជាតិដឹកនាំពេលជួបភ្ញៀវបរទេស
- ❖ ជួយបកប្រែពីភាសាបារាំង ឬ អង់គ្លេសមកជាភាសាខ្មែរនូវឯកសារចាំបាច់តាមតម្រូវការ
- ❖ រៀបចំតាក់តែងលិខិតបទដ្ឋានផ្សេងៗជាភាសាបារាំង និងភាសាអង់គ្លេសតាមការសម្រេចរបស់ថ្នាក់ដឹកនាំ
- ❖ ស្រាវជ្រាវឯកសារតាម Internet ពាក់ព័ន្ធនឹងជំនាញបកប្រែភាសាដើម្បីបង្កើនសមត្ថភាព
- ❖ អនុវត្តតាមក្រមសីលធម៌ និងរក្សាការសម្ងាត់វិជ្ជាជីវៈ
- ❖ អនុវត្តការងារផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

### ១.២.៣.៣. នាយកដ្ឋានស្រាវជ្រាវ តម្កល់ឯកសារ និងបណ្ណាល័យ

នាយកដ្ឋានស្រាវជ្រាវ តម្កល់ឯកសារ និងបណ្ណាល័យស្ថិតនៅក្រោមឱវាទប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។

នាយកដ្ឋាននេះមានការិយាល័យចំនួន២ នៅក្រោមឱវាទគឺ ៖

#### ក. ការិយាល័យស្រាវជ្រាវ និងតម្កល់ឯកសារ

ការិយាល័យស្រាវជ្រាវ និងតម្កល់ឯកសារស្ថិតនៅក្រោមឱវាទប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។ ការិយាល័យនេះមានមុខងារដូចតទៅ ៖

- ❖ សិក្សាស្រាវជ្រាវរាល់លិខិតបទដ្ឋានគតិយុត្តិទាក់ទងនឹងក្រុមប្រឹក្សាធម្មនុញ្ញ ឬ តុលាការធម្មនុញ្ញទាក់ទងឯកសារជាតិ ឯកសារអន្តរជាតិ ពិសេសលើវិស័យច្បាប់ សេដ្ឋកិច្ច សង្គម និងរដ្ឋបាលដូចជាក្នុងសមាគម តុលាការធម្មនុញ្ញនៃបណ្តាប្រទេសដែលប្រើភាសាបារាំង (ACCPUF) ដើម្បីឆ្លើយតបតាមតម្រូវការរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ឬ របស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

- ដកស្រង់ព័ត៌មានគ្រប់យ៉ាងពាក់ព័ន្ធដល់ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ឬ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលផ្សព្វផ្សាយតាម វិទ្យុ ទូរទស្សន៍ សារព័ត៌មាន រួចរាយការណ៍ជូនថ្នាក់ដឹកនាំ
- រៀបចំទុកដាក់តាមបច្ចេកទេសតម្កល់ឯកសារទាំងឡាយដែលនាយកដ្ឋានជំនាញនីមួយៗបានប្រគល់ឱ្យ ដោយបញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ
- ធ្វើការទាក់ទងជាមួយអង្គភាពរដ្ឋ និងសង្គមស៊ីវិល ឬ អង្គការនានា ដោយមានការយល់ព្រមជាមុនពីអគ្គលេខាធិការ និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីបង្កើនសមត្ថភាពយល់ដឹងជំនាញក្នុងការគ្រប់គ្រង និងការថែទាំឯកសារឱ្យបានគង់វង្ស
- អនុវត្តតាមក្រមសីលធម៌ និងរក្សាការសម្ងាត់វិជ្ជាជីវៈ
- អនុវត្តការងារផ្សេងៗទៀតដែលប្រធាននាយដ្ឋានប្រគល់ជូន ។

**ខ. ការិយាល័យគ្រប់គ្រងបណ្ណាល័យ**

ការិយាល័យគ្រប់គ្រងបណ្ណាល័យ ស្ថិតនៅក្រោមឱវាទប្រធានការិយាល័យមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។

ការិយាល័យនេះមានមុខងារដូចតទៅ ៖

- រៀបចំសៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី រាជកិច្ច ទុកដាក់ឱ្យបានត្រឹមត្រូវតាមប្រភេទនីមួយៗ និងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសបណ្ណាល័យ ដោយបានបោះត្រា ចុះបញ្ជី ធ្វើកាតាឡុក ព្រមទាំងបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រឱ្យបានគ្រប់ចំនួន និងច្បាស់លាស់
- ធ្វើគម្រោងជូនអគ្គលេខាធិការ ដើម្បីសុំអំណោយសៀវភៅ ឯកសារពីស្ថាប័នរដ្ឋ ឯកសារក្នុងប្រទេស ឬ ក្រៅប្រទេស
- ធ្វើគម្រោងជូនអគ្គលេខាធិការដើម្បីសុំទិញ ជាវសៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី សារព័ត៌មាន ។ល។
- ចាត់តាំងចងក្រង ដេរភ្ជាប់បញ្ចូលគ្នានូវឯកសារគ្រប់ប្រភេទ និងតាមត្រីមាស ឆមាស ឬ តាមឆ្នាំ
- តាមដានជាប្រចាំនូវបញ្ជីចុះឈ្មោះអ្នកខ្ចីសៀវភៅពីបណ្ណាល័យ អ្នកសងសៀវភៅមកវិញ ធ្វើគោលការណ៍បែងចែកសៀវភៅ ទស្សនាវដ្តី ព្រឹត្តិបត្រ ដែលស្ថាប័នរដ្ឋ អង្គការនានាផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញដោយត្រូវមានតម្កល់ទុកជាឯកសារក្នុងបណ្ណាល័យ
- អនុវត្តតាមក្រមសីលធម៌ និង រក្សាការសម្ងាត់វិជ្ជាជីវៈ
- អនុវត្តការងារផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន ។

### ១.២.៤. នាយកដ្ឋានសវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុងស្ថិតនៅក្រោមឱវាទប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនសមស្រប ។

នាយកដ្ឋាននេះមានមុខងារដូចតទៅ ៖

- កសាងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំជូនប្រធានស្ថាប័នពិនិត្យ និងសម្រេច
- ពិនិត្យលើឥណទាន សកម្មភាពប្រតិបត្តិការ កម្មវិធី ផែនការ និងប្រព័ន្ធដែលបានបង្កើតដើម្បីធានាឱ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព
- ពិនិត្យលើការគ្រប់គ្រង ថែទាំ ការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឱ្យបានត្រឹមត្រូវ
- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍន៍ ការអនុវត្ត និងកិច្ចប្រតិបត្តិការតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីការត្រួតពិនិត្យផ្ទៃក្នុងត្រូវបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ
- សម្របសម្រួលសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិ
- ធ្វើរបាយការណ៍ និងការសន្និដ្ឋានជូនប្រធានស្ថាប័ន និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ
- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។[11]

## ១.៣.ការជ្រើសតាំងសមាជិក ការដាក់ពិន័យ និងការដកពីដំណែង

### ១.៣.១. ការតែងតាំង និងជ្រើសតាំង

ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យនិងអព្យាក្រឹតក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក៩រូប ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានអាណត្តិ ៩ឆ្នាំ។

សមាជិកទាំង៩រូប នៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ឆ្នាំ មានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូតឬខាងសេដ្ឋកិច្ច ហើយមានបទពិសោធន៍ក្នុងការងារយ៉ាងតិច ១៥ឆ្នាំ ។

([11]). ឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេច ស្តីពី ការកែសម្រួលរចនាសម្ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ៣រូប ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម៣រូប ទៀតត្រូវតែងតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃសមាជិកនៃរដ្ឋសភាទាំងមូល ។

ការជ្រើសតាំងដោយរដ្ឋសភាអាចធ្វើឡើងជាពីលើកបាន ។

ក្នុងអាណត្តិទី១ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលទទួលបានសំឡេងច្រើនជាងគេចំនួនយ៉ាងច្រើន៥រូបមកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី២ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។ អ្នកដែលទទួលបានសំឡេងច្រើនជាងគេត្រូវតែងតាំងសម្រាប់ ៩ឆ្នាំ អ្នកដែលទទួលបានសម្លេងបន្ទាប់ត្រូវតែងតាំងសម្រាប់ ៦ឆ្នាំ និងអ្នកដែលទទួលបានសឡេងបន្ទាប់មកទៀតត្រូវតែងតាំងសម្រាប់៣ឆ្នាំ ។

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតលើកទី ២ ដោយយកអ្នកដែលទទួលបានសំឡេងច្រើនជាងគេចំនួន២នាក់នោះបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី២ ត្រូវយកតាមសំឡេងភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលបេក្ខជនសម្លេងស្មើគ្នានោះ ត្រូវយកអ្នកដែលមានអាយុច្រើនជាងគេ ។

បេក្ខជនម្នាក់ៗដែលនឹងត្រូវជ្រើសតាំងដោយរដ្ឋសភា ត្រូវមានហត្ថលេខាគាំទ្រជាមុនពីសមាជិករដ្ឋសភាចំនួនមួយភាគដប់នៃសមាជិកទាំងមូល ។ សមាជិករដ្ឋសភា ១រូបមានសិទ្ធិគ្រាំទ្របានតែបេក្ខជន ១រូបប៉ុណ្ណោះ។[12]

ក្នុងរយៈពេលបីឆ្នាំម្តង មានសមាជិកចំនួន ៣ រូប ត្រូវផ្លាស់ប្តូរ និងតែងតាំងជាថ្មីគឺ ១ រូបតែងតាំងដោយព្រះមហាក្សត្រ ១ រូប តែតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម១រូប និង ១ រូបទៀតជ្រើសតាំងដោយរដ្ឋសភា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសតាមការបោះឆ្នោត ដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរៀងរាល់ ៣ ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្រោយពីសមាជិក ៣ រូបចូលកាន់តំណែង ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់អាចត្រូវបានជ្រើសតាំងជាថ្មីបាន ។

([12] ). មាត្រា៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា។[13]

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹងមុខងារ ជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា ប្រធាន អនុប្រធានគណៈបក្សនយោបាយ ប្រធាន អនុប្រធាសហជីព និង ចៅក្រមក្នុងតំណែង ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវបំពេញមុខតំណែង និងមុខរបរផ្សេងទៀតនៅក្នុង អាណត្តិ របស់ខ្លួនឡើយ ។

អ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ មុនចូលកាន់តំណែងត្រូវសុំលាឈប់ ជាបណ្ដោះអាសន្នពីតំណែង ឬ មុខរបរទាំងអស់ ដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិក ដែលនៅក្នុងមុខ តំណែង និងមុខរបរ ខាងលើ ឲ្យសុំលាឈប់ពីមុខតំណែង ឬ មុខរបរនោះជាបន្ទាន់ ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសុំដកខ្លួនចេញពីរឿងទាំងឡាយណា ដែលផលជាប្រយោជន៍ផ្ទាល់ខ្លួនពាក់ព័ន្ធក្នុងរឿងនោះ ។ ការសុំដកខ្លួន ឬ ការតម្រូវឲ្យដកខ្លួន ឬ សម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។[14]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំងជំនួសយ៉ាងយូរ ៣០ ថ្ងៃ មុនចប់អាណត្តិរបស់សមាជិកដែលត្រូវចេញពីតំណែង ។

ក្នុងករណីមានការសុំលាឈប់ ឬ ការដកចេញពីតំណែង ឬ មរណភាព សមាជិកថ្មីមកជំនួសត្រូវតែងតាំងដូចមានចែងក្នុងមាត្រា៤ ក្នុងរយៈពេល ៣០ ថ្ងៃ យ៉ាងយូរ ។[15]

មុនចូលកាន់តំណែង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើសច្ចាប្រណិធាន ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវរក្សាការសម្ងាត់ក្នុងការពិភាក្សា និងការបោះឆ្នោត ហើយមិនត្រូវបញ្ចេញយោបល់របស់ខ្លួនក្រៅអង្គប្រជុំទេ ។[16]

---

([13]). មាត្រា៤ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

([14]).មាត្រា៥ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

([15]).មាត្រា៦ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

សមាជិកថ្មីនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវបានតែងតាំងជំនួសសមាជិក ដែលត្រូវចេញពីមុខតំណែងមុនចប់អាណត្តិធម្មតារបស់ខ្លួន មានអាណត្តិត្រឹមថេរវេលានៅសល់ប៉ុណ្ណោះ ។

ប៉ុន្តែបើថេរវេលានេះតិចជាង ៣ ឆ្នាំ ឬ ស្មើនឹង ៣ ឆ្នាំ នៅពេលចប់ថេរវេលានេះ សមាជិកនោះ អាចត្រូវបានគេតែងតាំង ឬ ជ្រើសតាំង សម្រាប់អាណ្តិថ្មីមួយអាណត្តិទៀតបាន ។[17]

### ១.៣.២. ការដាក់ពិន័យ ការដកពីតំណែង

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញម្នាក់ៗ អាចសុំលាឈប់ពីតំណែងបាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ។[18]

ក្រុមប្រឹក្សាធម្មនុញ្ញអាចដកចេញពីតំណែងនូវសមាជិកណា ដែលរំលោភលើមាត្រា ៥ និង ៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឬ ដែលមិនបានមកប្រជុំលើសពី ៣ដងជួនៗ គ្នាដោយឥតជូនដំណឹងជាមុន ឬ មុនបានបំពេញមុខងារជារៀងរហូតបាន ដោយបាត់បង់សមត្ថភាពខាងបញ្ញា ឬ រូបកាយជាអចិន្ត្រៃយ៍ ។

ការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាមួយពីតំណែង តម្រូវឲ្យមានការយល់ព្រមពីសមាជិកចំនួន ពីរភាគបីនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាដែលត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ត្រូវដកចេញពីតំណែងដោយស្វ័យប្រវត្តិ ។[19]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមិនគោរពតាមបទបញ្ញត្តិ នៃច្បាប់ស្តីពីការរៀបចំ និងការព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្តន្ទាទោសខាងបទវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

សមាជិកដែលមិនគោរពបទបញ្ជាផ្ទៃក្នុងត្រូវផ្តន្ទាទោសខាងបទវិន័យ។

ទណ្ឌកម្មខាងវិន័យចំពោះក្រុមប្រឹក្សាធម្មនុញ្ញមាន

១. ក្រើនរំឭកដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

(16).មាត្រា៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

(17).មាត្រា៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

(18). មាត្រា៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

(19).មាត្រា១០ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

២. ក្រើនរំឭកដោយមានចុះកំណត់ហេតុនៅលើកទី២ ដោយប្រធាន

៣. ស្តីបន្ទោសដោយធ្វើជាលាយលក្ខណ៍អក្សរ ។[20]

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវក្រើនរំឭកដែលធ្វើខុសដដែលៗ ក្នុងរយៈពេល ៣០ថ្ងៃ ឬខូចសណ្តាប់ធ្នាប់ដោយល្មើស នឹងប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងនេះ ។[21]

សមាជិកណាដែលត្រូវក្រើនរំឭក ៣ដង ហើយនៅតែប្រព្រឹត្តខុស ត្រូវក្រើនរំឭកដោយមានចុះកំណត់ហេតុ ។ វិន័យនេះនាំឱ្យមានការកាត់ប្រាក់បំណាច់ប្រចាំខែរបស់សមាជិកនោះចំនួន១ភាគ៤ ។[22]

ត្រូវទទួលទណ្ឌកម្មវិន័យស្តីបន្ទោសសមាជិកណាដែល

- នាំឱ្យជ្រួលច្របល់ក្នុងសាលប្រជុំ ឬក្រៅសាលប្រជុំ ឬនាំអាទ៍ឱ្យសមាជិកច្រើននាក់មិនចូលរួមធ្វើការក្នុងក្រុមប្រឹក្សាធម្មនុញ្ញ
- ប្រមាថមើលងាយ ឬបង្កជម្លោះ ឬគំរាមកំហែងសមាជិកដទៃទៀត ឬញុះញង់សមាជិកដទៃទៀតឱ្យប្រើហិង្សា
- មើលងាយក្រុមប្រឹក្សាធម្មនុញ្ញ ឬប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
- ប្រមាទមើលងាយព្រះមហាក្សត្រ វិន័យស្តីបន្ទោសនាំឱ្យមានការកាត់ប្រាក់បំណាច់ប្រចាំខែរបស់សមាជិកនោះចំនួន ៥០%រយៈពេលពីរខែ ។[23]

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវទទួលវិន័យតាម ប្រការ២៤ ប្រការ២៥ នៃបទបញ្ជាផ្ទៃក្នុងនេះក្រោយពីបានទទួលសំណុំរឿងផ្ទាល់ខ្លួន ត្រូវធ្វើការដោះសាក្នុងរយៈពេល ៥ថ្ងៃ។

ផុតកំណត់នេះ ទោះបីសាមីខ្លួនធ្វើការដោះស្រាយ ឬមិនដោះស្រាយក្តី ក្រុមប្រឹក្សាធម្មនុញ្ញដាក់វិន័យតាមមតិភាគច្រើនដូចមានចែងក្នុង ប្រការ១៨ និង ១៩ នៃបទបញ្ជា ។[24]

---

([20]). ប្រការ ២២ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុង ស្តីពី នីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

([21]). ប្រការ ២៣ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុង ស្តីពី នីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

([22]).ប្រការ ២៤ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុង ស្តីពី នីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

([23]).ប្រការ ២៥ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុង ស្តីពី នីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

ការដកសមាជិកណាមួយពីក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុលោមតាម មាត្រា១០ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

ការសុំលាឈប់ពីតំណែងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញអាចប្រព្រឹត្តទៅបាន លុះត្រាតែសមាជិកនោះបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រុមប្រឹក្សាធម្មនុញ្ញ និងក្រោយពីស្ថាប័នមានសមត្ថកិច្ចតែងតាំងឬជ្រើសតាំង ដើម្បីស្ថាប័ននោះតែងតាំង ឬជ្រើសតាំងសមាជិកថ្មីមកជំនួស ។

ក្នុងការអនុវត្ត ប្រការ២៧ នេះក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែជូនដំណឹងភ្លាមទៅស្ថាប័នដែលមានសមត្ថកិច្ចតែងតាំង ឬជ្រើសតាំង ដើម្បីស្ថាប័នទាំងនោះតែងតាំង ឬជ្រើសតាំងសមាជិកថ្មីជំនួស ។[២៥]

ការដកសមាជិកណាមួយពីក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមនេះៈ

**១.** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជូនដំណឹងទៅសមាជិកដែលត្រូវដកចេញថាគេមានពេលវេលា១៥ថ្ងៃចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ដើម្បីសារណាការពារខ្លួន ។

**២.** ផុតពេលនេះទោះបីសាមីខ្លួន មិនបានផ្ញើសារណាការពារខ្លួនមកក្រុមប្រឹក្សាធម្មនុញ្ញក៏ដោយ ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនការ សម្រេចលើករណីរឿងនេះបាន ។

ក្នុងពេលសវនការ សាមីខ្លួនអាចអញ្ជើញមកការពារខ្លួនមុខក្រុមប្រឹក្សាធម្មនុញ្ញ ឬចាត់តាំងតំណាង ឬមេធាវី មកការពារខ្លួនក៏បាន ។[26]

([24]).ប្រការ ២៦ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុង ស្តីពី នីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

([25]).ប្រការ ២៧ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុង ស្តីពី នីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

([26]).ប្រការ ២៧ស្ទួន នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុង ស្តីពី នីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

# ជំពូកទី២ ការពិនិត្យធម្មនុញ្ញភាព

# ជំពូកទី២ ការពិនិត្យធម្មនុញ្ញភាព

## ២.១.ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់

ការពិនិត្យធម្មញ្ញភាពនៃច្បាប់ គឺជាការត្រួតពិនិត្យទៅលើអត្ថបទច្បាប់ ថាតើវាស្របទៅនឹងរដ្ឋធម្មនុញ្ញឬមិនស្របទៅនឹងរដ្ឋធម្មនុញ្ញ។ បើច្បាប់នោះបានពិនិត្យហើយវាស្របនឹងរដ្ឋធម្មនុញ្ញ គេថាច្បាប់នោះមានធម្មនុញ្ញភាព ប្រសិនបើច្បាប់នោះបានពិនិត្យហើយ មិនស្របនឹងធម្មនុញ្ញ គេថាច្បាប់នោះវាអធម្មនុញ្ញភាព។ ជាទូទៅការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់គឺមានពីរបែបគឺការត្រួតពិនិត្យជា **អាទិកាល** និងការត្រួតពិនិត្យជា **បច្ឆាកាល** ។

### ២.១.១ ការពិនិត្យជាអាទិកាល

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រួតពិនិត្យសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញដែលព្រះមហាក្សត្រត្រូវតែពិគ្រោះយោបល់ប្រឹក្សាធម្មនុញ្ញជាមុន។ មាត្រា ១៤៣ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។

ក្រោយពីរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ច្បាប់រៀបចំអង្គការ ឬវិសោធនកម្មនៃច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និង បទបញ្ជាផ្ទៃក្នុង ឬនិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់ហើយត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យថាតើច្បាប់នោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងប្រកាសឲ្យប្រើ។[27]

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន តំណាងរាស្ត្រមួយភាគដប់ ឬតុលាការ អាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឲ្យប្រើ។[28]

### ២.១.២ ការពិនិត្យជាបច្ឆាកាល

ក្រោយពីច្បាប់ណាមួយ ត្រូវបានប្រកាសឲ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួនតំណាងរាស្ត្រមួយភាគបួន ឬសមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬតុលាការ អាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ ។

([27])មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

([28] )មាត្រា ១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ប្រជារាស្ត្រមានសិទ្ធិប្តឹងពីធម្មនុញ្ញភាពនៃច្បាប់បានតាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ។[29]

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ បន្ទាប់ពីច្បាប់នោះត្រូវបានប្រកាសឲ្យប្រើ។ បុគ្គលដែលមានសមត្ថកិច្ច អាចសុំទៅក្រុមប្រឹក្សាធម្មនុញ្ញថែងថាក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឲ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬតុលាការ ក៏អាចស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពក្រោយច្បាប់ត្រូវបានប្រកាសឲ្យប្រើហើយ (មាត្រា ១៤១ថ្មី នៃវាក្យខ័ណ្ឌទី១នៃធម្មនុញ្ញ)។

រួមបញ្ចូលទាំងតុលាការដែលអាច ភាគីដែលជាគូក្តី ឬ ចៅក្រមខ្លួនឯងអាចលើកឡើងនូវអញ្ញត្រកម្មអធម្មនុញ្ញភាពនៃច្បាប់ ។ នៅក្នុងរដ្ឋធម្មនុញ្ញមិនបានកំណត់នូវលក្ខខណ្ឌការត្រួតពិនិត្យធម្មនុញ្ញភាពដោយអញ្ញត្រកម្មនេះទេ ។ ក៏ប៉ុន្តែបុគ្គលដែលជាប់ពាក់ពន្ធ័ក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនូវបទបញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័ននានា ដែលគេអះអាង ថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន ។[30] សិទ្ធិប្តឹងទៅតុលាការអាចជាសិទ្ធិរបស់ដើមចោទ ចុងចោទក៏ដូចជារបស់គូភាគីនៅតុលាការដែរ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គេបន្ថែមថាការលើកឡើងនេះ មានមូលដ្ឋានគ្រប់គ្រាន់តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ ។[31]

ចំនុចនេះចៅក្រមវាយតម្លៃពីភាពមានមូលដ្ឋានច្បាស់លាស់នៃបណ្តឹង ប្រសិនបើចៅក្រមយល់ថាមានមូលដ្ឋានច្បាស់លាស់ ចៅក្រមត្រូវបញ្ជូនសំណុំរឿងទៅតុលាការកំពូលដែលត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ ហើយតុលាការកំពូលត្រូវចាត់ការពិនិត្យនិងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថាពាក្យបណ្តឹតវ៉ានេះមិនអាចទទួលបាន ។[32]

តុលាការកំពូលនៅពេលនេះធ្វើការជម្រុះ ដោយពិនិត្យជាលើកទីពីរ មុនបញ្ជូនបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

(29)មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

(30 )មាត្រា ១៩ វាក្យខណ្ឌទី ១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

(31 )មាត្រា១៩ វាក្យខ័ណ្ឌទី ២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

(32 )មាត្រា១៩ វាក្យខណ្ឌទី ៣ នៃច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃធម្មនុញ្ញ

បញ្ញត្តិនេះ មានលក្ខណៈគួរឲ្យកត់សម្គាល់យ៉ាងខ្លាំង ដោយសារតែវាមានវិសាលភាពទៅដល់ការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល ដែលធ្វើឲ្យក្រុមប្រឹក្សាធម្មនុញ្ញ អាចពិនិត្យបានដោយមានបណ្តឹងពីគូភាគីក្នុងរឿងក្តី ។

លទ្ធភាពឲ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពបច្ឆាកាល ជាការធានាជាអតិបរមានូវការគោរពនីតិរដ្ឋ តាមរយៈការត្រួតពិនិត្យធម្មនុញ្ញភាពដែលមានលក្ខណៈពេញលេញបំផុត ។

## ២.២. អំពីការប្តឹង

### ២.២.១ គោលការណ៍ទូទៅ

ជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយករឿងណាមួយមកពិនិត្យខ្លួនឯង ដោយគ្មានអ្នកមានសមត្ថកិច្ចស្នើសុំ ឬប្តឹងបានទេ ។ រហូតមកដល់ពេលនេះ ក្រុមប្រឹក្សាធម្មនុញ្ញនៅតែប្រកាន់តាមគោលការណ៍នេះ ។

### ២.២.២.អ្នកណាខ្លះអាចស្នើសុំ/ប្តឹងបាន

- **.ព្រះមហាក្សត្រ**

- ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើធម្មនុញ្ញ ។
- ការផ្តើមគំនិតសើរើឬការផ្តើមគំនិតធ្វើវិសោធនកម្មលើធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្ររបស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសើចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃសមាជិករដ្ឋសភាទាំងមូល។




**កំណត់សម្គាល់**

1 : ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយណាដែលសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ

2 : ធ្វើសំណើថ្វាយព្រះមហាក្សត្រទ្រង់ព្រះតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ

3 : មតិក្រុមប្រឹក្សាធម្មនុញ្ញថ្វាយព្រះមហាក្សត្រ

4 : ព្រះរាជសារទៅម្ចាស់សំណើវិញ

❖ **ប្រជារាស្ត្រ**

ប្រជារាស្ត្រអាចលើកឡើងប្តឹងទៅតុលាការ អំពីបញ្ហាធម្មនុញ្ញភាពនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័ននានារបស់រដ្ឋ ដូចជាព្រះរាជក្រឹត្យ ប្រកាស និង សេចក្តីសម្រេចរដ្ឋបាលផ្សេងៗ តាមរយៈរឿងក្តីរបស់ខ្លួន នៅតុលាការ ។ តុលាការថ្នាក់ក្រោមបញ្ជូនពាក្យបណ្តឹងខាងលើនេះទៅតុលាការកំពូល ។

តុលាការកំពូលជាអ្នកបញ្ជូនបណ្តឹងនោះបន្តមកក្រុមប្រឹក្សាធម្មនុញ្ញ ប្រសិនបើតុលាការកំពូលយល់ឃើញថាសមហេតុផល ។ បញ្ហាដែលកើតឡើងនោះជាបញ្ហាបន្ទាន់បង្ខំដែលតុលាការទទួលបន្ទុកជំនុំជម្រះត្រូវផ្អាកសិន ដោយរង់ចាំចម្លើយ របស់ក្រុមប្រឹក្សាធម្មនុញ្ញជាមុន ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកជួយពិនិត្យធម្មនុញ្ញភាពជូនប្រជារាស្ត្រក្នុងករណីនេះ ។

- ក្នុងករណីគ្មានរឿងក្តីក៏ដោយ ប្រជារាស្ត្រមានសិទ្ធិប្តឹងសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ណាដែលប្រកាសឱ្យប្រើហើយ ។ ប្រជារាស្ត្រត្រូវប្តឹងតាមរយៈប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាចំនួន មួយភាគបួន ឬ តំណាងរាស្ត្រមួយភាគដប់ ។
- ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចជូនប្រជារាស្ត្រអំពីករណីវិវាទកម្មទាក់ទងនឹងរឿងបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាក្នុងករណីដែលប្រជារាស្ត្រមិនសុខចិត្តនឹងសេចក្តីសម្រេច ។




I. បណ្តឹងពិនិត្យធម្មនុញ្ញភាពនៃច្បាប់ II. បញ្ហាបន្ទាប់បន្សំ

III. បណ្តឹងទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង សមាជិកព្រឹទ្ធសភា

<u>**កំណត់សម្គាល់**</u>

❶ : មានសិទ្ធិប្តឹងសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ណាដែលប្រកាសឱ្យប្រើហើយ

❷ : ប្តឹងអំពីបញ្ហាអធម្មនុញ្ញភាព តាមរយៈតុលាការទទួលរឿងក្តី

❸ : ប្តឹងជំទាស់មកក្រុមប្រឹក្សាធម្មនុញ្ញ មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប.

❖ **ក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ**

- ក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ ក្នុងក្របខណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាព តាមសំណើពីព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួន មួយភាគបួន ឬតំណាងរាស្ត្រមួយភាគដប់ ឬតុលាការ "តុលាការចំពោះតែ
- ច្បាប់ណាដែលប្រកាសឱ្យប្រើហើយ" ។
- ក្រុមប្រឹក្សាធម្មនុញ្ញអាចពិនិត្យជាអាទិកាល ឬបច្ឆាកាល នូវធម្មនុញ្ញភាពនៃច្បាប់ក្នុងលក្ខខណ្ឌខាងលើ លើកលែងតែច្បាប់ រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ដែលត្រូវតែពិនិត្យមុន នឹងប្រកាសឱ្យប្រើ (ឬ មុននឹងដាក់ឱ្យអនុវត្ត) ។
- ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនៃការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ

បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើគ្រប់អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។




❖ **គណបក្សនយោបាយ**

- ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និង សម្រេចលើបណ្តឹងរបស់គណបក្សនយោបាយ ដែលក្រសួងមហាផ្ទៃបាន បដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយ ។
- ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ សម្រេចជូនគណបក្សនយោបាយ តាមបណ្តឹងផ្ទាល់ ( បណ្តឹងនេះធ្វើបានរយៈពេល ៧២ ម៉ោងយ៉ាងយូរបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន )ឬតាមបណ្តឹង ឧទ្ធរណ៍មិនសុខចិត្ត និងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- ក្នុងការដោះស្រាយវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្របោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការដោះស្រាយបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នឹងបញ្ជីដំបូងនៃការចុះឈ្មោះបោះឆ្នោត និងដំណោះស្រាយបណ្តឹងក្នុងពេលឃោសនាបោះឆ្នោតក្រុមប្រឹក្សាធម្មនុញ្ញបំពេញតួនាទីដូចតុលាការ ។
- វិវាទកម្មទាក់ទងនឹងការបោះឆ្នោតមានដូចជា ៖
  - ➢ បណ្តឹងតវ៉ារបស់គណបក្សនយោបាយ ឬ បុគ្គលដែលដែលតវ៉ាអំពីបេក្ខភាព ឬសម្រេចបដិសេធលើការតវ៉ាបញ្ជីរាយនាមបេក្ខជនឈរឈ្មោះដែលបានសម្រេចដោយ គ.ជ.ប ហើយពួកគេមិនសុខចិត្ត

- បណ្តឹងតវ៉ារបស់បុគ្គល ដែលប្តឹងមិនសុខចិត្តនិងសើចក្តីសម្រេចរបស់ គ.ជ.ប
- ដែលបដិសេធការតវ៉ាចុះឈ្មោះ បណ្តឹងតវ៉ារបស់បុគ្គល ឬ អ្នកតំណាងរាស្ត្រ ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប អំពីការបាត់ឈ្មោះ ជំទាស់និងការចុះឈ្មោះ បណ្តឹងតវ៉ាផ្ទាល់អំពីលទ្ធផលនៃការបោះឆ្នោតដែលបុគ្គល ឬគណបក្សនយោបាយមិនសុខចិត្ត
- បណ្តឹងតវ៉ាបុគ្គល ឬគណបក្សនយោបាយមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប




**កំណត់សម្គាល់**

❶ : បណ្តឹងរបស់គណបក្សនយោបាយដែលក្រសួងមហាផ្ទៃបានបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយ

❷ : បណ្តឹងឧទ្ធរណ៍មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប. ( រយៈពេលមាន ៥ ថ្ងៃ ឬ ៧២ ម៉ោង ទៅតាមករណីនីមួយៗ )

❸ : បណ្តឹងផ្ទាល់មិនសុខចិត្តអំពីលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ប្រកាសដោយ គ.ជ.ប.

## ២.៣.ដំណើរការនៃសំណុំរឿងនៅនាយកដ្ឋានជំនាញ

នៅពេលទទួលបានសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ នាយកដ្ឋានជំនាញចុះបញ្ជីក្នុងសៀវភៅទទួលសំណុំរឿង ។ ក្រោយពីចុះបញ្ជីរួច នាយកដ្ឋានត្រូវរៀបចំកំណត់បង្ហាញរឿងដាក់ឆ្លងតាមឋានានុក្រមរហូតដល់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ និងសម្រេច ។ ការងារបន្ទាប់របស់នាយកដ្ឋានជំនាញគឺជួយ ដល់ក្រុមប្រឹក្សាធម្មនុញ្ញដូចជា រៀបចំសំណុំរឿងសម្រាប់កិច្ចប្រជុំ

ក្រុមប្រឹក្សាធម្មនុញ្ញ រៀបចំកម្មវិធីលម្អិតជូនថ្នាក់ដឹកនាំសម្រាប់កិច្ចប្រជុំទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធដើម្បីស្រាវជ្រាវរកឯកសារ តាមតម្រូវការសមាជិករាយការណ៍របស់ក្រុមប្រឹក្សាធម្មនុញ្ញចូលរួមជាជំនួយការលេខាធិការកត់ត្រា និងធ្វើកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

### ២.៣.១. នីតិវិធិដែលត្រូវអនុវត្ត

ដើម្បីអនុវត្តការងារឲ្យមានប្រសិទ្ធិភាព និងរលូន ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានបែងចែកជា ៣ ក្រុម ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសតាំងសមាជិកព្រឹទ្ធសភា ក៏ដូចជាការស្រាវជ្រាវត្រួតពិនិត្យធម្មនុញ្ញភាព ឬសមាជិកតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង១រូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្នុងក្រុមទាំងបីនេះត្រូវជ្រើសរើសដោយដោយវិធីចាប់ឆ្នោត ក្រោមអធិបតីនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។[33]

ប្រការ៤ នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានចែងថា ក្រុមនីមួយៗនៃក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ៣រូប ដែលមួយរូបជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ មួយរូបជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងមួយរូបទៀតជាសមាជិកជ្រើសតាំងដោយរដ្ឋសភា ។

សមាជិកទាំងនេះ ត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

#### ២.៣.១.១. ការចាត់តាំងសមាជិករាយការណ៍

នៅពេលច្បាប់ដែលត្រូវបានស្នើសុំមកក្រុមប្រឹក្សាធម្មនុញ្ញ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាត់តាំងសមាជិកម្នាក់ឲ្យធ្វើជាសមាជិករាយការណ៍។ របាយករណ៍របស់សមាជិករាយការណ៍ជាមូលដ្ឋានសំខាន់មួយសម្រាប់ពិចារណា។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ឬបកស្រាយច្បាប់ ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិកដែលប្រធានបានប្រគល់ភារកិច្ចឲ្យពិនិត្យរាយការណ៍ ។[34] សមាជិករាយការណ៍ជាសមាជិកនៃក្រុមរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលមានចែងក្នុងមាត្រា៣០ នៃច្បាប់នេះ ។

ប្រការ៣ថ្មី នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានចែងថា ក្រោយពីចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនសំណើទាំងនោះទៅសមាជិករាយ

(33)មាត្រា ៣០ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

(34)មាត្រា ២២ថ្មីវាក្យខ័ណ្ឌទី២ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ការណ៍ក្នុងក្រុមណាមួយនៃក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ។ របាយការណ៍របស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវដាក់ជូនអង្គប្រជុំបឋមដើម្បីពិភាក្សា ។

### ២.៣.១.២. ភារកិច្ចរបស់សមាជិករាយការណ៍

បន្ទាប់ពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាត់តាំងសមាជិករាយការណ៍ សមាជិករាយការណ៍ត្រូវកោះប្រជុំក្រុមដោយមានមន្ត្រីសេវាកម្មច្បាប់ចូលរួមជាលេខាធិការកត់ត្រា ។ សមាជិករាយការណ៍អាចស្នើសុំប្រធានក្រុមប្រឹក្សាធម្មនុញ្ញឲ្យអញ្ជើញបុគ្គលឯកជនឬបុគ្គលសាធារណៈម្នាក់ ឬច្រើននាក់ដើម្បីសុំឲ្យអ្នកទាំងនោះផ្តល់ការបំភ្លឺឬផ្តល់ឯកសារផ្សេងៗទាក់ទងនឹងសំណុំរឿងដែលកំពុងពិនិត្យ ។ ការអញ្ជើញចាំបាច់ត្រូវតែមានចំពោះសម្រាប់បុគ្គលផ្សេងៗដែលពាក់ព័ន្ធ ក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិអញ្ជើញជនណាម្នាក់ ឬច្រើននាក់មកបំភ្លឺ ឬផ្តល់ឯកសារដែលពាក់ពន្ធ័បាន ។ បុគ្គលគ្រប់រូបស្ថាប័នរដ្ឋ ឬឯកជនទាំងឡាយ ត្រូវគោរព និងប្រតិបត្តិតាមការអញ្ជើញ និងការស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។[35]

ក្រោយពីសិក្សាលើច្បាប់ហើយ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើរបាយការណ៍ស្តីពី ការពិនិត្យធម្មនុញ្ញភាពដើម្បីដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញនាសម័យប្រជុំបឋមដើម្បីពិនិត្យ និងពិភាក្សា។

([35])មាត្រា ២១នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមក្រុមប្រឹក្សាធម្មនុញ្ញ

# ជំពូកទី៣.សមត្ថកិច្ចនានារបស់ក្រុម
# ប្រឹក្សាធម្មនុញ្ញ

# ជំពូកទី៣.សមត្ថកិច្ចនានារបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## ៣.១.សមត្ថកិច្ចបកស្រាយច្បាប់

### ៣.១.១ និតិវិធីក្នុងការបកស្រាយច្បាប់

ដោយអនុលោមទៅតាមមាត្រា ១៥ ១៦ ១៧ ១៨ និងមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលសំណើពីព្រះមហាក្សត្រ ពីប្រធានរដ្ឋសភា ពីនាយករដ្ឋមន្ត្រី ពីតំណាងរាស្ត្រមួយភាគដប់ ពីតុលាការ ពីប្រជារាស្ត្រតាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រមួយភាគដប់ ឬពីតុលាការកំពូល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចាត់ឲ្យចុះបញ្ជីនៅអគ្គលេខាធិការដ្ឋាន។[36]

រយៈពេលដោះស្រាយត្រូវចាប់រាប់តាំងពីថ្ងៃចុះបញ្ជីនេះ ហើយពេលវេលាដោះស្រាយតាមការកំណត់ក្នុងច្បាប់។ ក្រោយពេលចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនសំណើទាំងនោះទៅក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ ។ របាយការណ៍របស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវដាក់ជូនសម័យប្រជុំបឋមដើម្បីចុះសៀវភៅដាក់រឿងជំនុំជំរះ ។ ក្រុមនីមួយៗ នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវដាក់ជូនសម័យប្រជុំបឋមដើម្បីចុះសៀវភៅដាក់រឿងជំនុំជំរះ ។ ក្រុមនីមួយៗ នៃក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ៣រូប ដែលមួយរូបជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ មួយរូបជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងមួយទៀតជាសមាជិកជ្រើសតាំងដោយរដ្ឋសភា។ សមាជិកទាំងបីក្រុមនេះ ត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ សមាជិករាយការណ៍ត្រូវតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងប្រតិបត្តិការងារសមាជិករាយការណ៍មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយគ្រាន់តែជូនពត៌មានទៅប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។[37]

ទោះក្នុងករណីណាក៏ដោយ សមាជិករាយការណ៍ត្រូវតែរាយការណ៍ជូនសម័យប្រជុំបឋមដើម្បីចុះក្នុងសៀវភៅដាក់រឿងជុំនុំជំរះ ។ របាយការណ៍នេះត្រូវដាក់ជូនអង្គប្រជុំពេញអង្គ ដើម្បីពិភាក្សា និងសម្រេចជាស្ថាពរ ។ ចំពោះគ្រប់សំណើរឲ្យពិនិត្យទាំងអស់នេះខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងពេលវេលាមួយ ដែលមានកំណត់ក្នុងច្បាប់ និងតាមមតិភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល( ៥សំឡេងយ៉ាងតិច ) ។[38]

### ៣.១.២ សេចក្តីសម្រេចក្នុងការបកស្រាយច្បាប់

([36] ).ប្រការ១នៃបទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខប្រឹក្សាធម្មនុញ្ញ

([37]). ប្រការ៥នៃបទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខប្រឹក្សាធម្មនុញ្ញ

([38]). ប្រការ៧នៃបទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអញ្ជើញជនណាម្នាក់ឬច្រើននាក់មកបំភ្លឺ ដល់ឯកសារដែលពាក់ព័ន្ធបាន ។ បុគ្គលគ្រប់រូប ស្ថាប័នរដ្ឋឬឯកជនទាំងឡាយ ត្រូវគោរពនិងប្រតិបត្តិតាមការអញ្ជើញនិងស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។[39]

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរលើគ្រប់ករណីដែលត្រូវបានដាក់ជូនក្នុងរយៈពេល ៣០ថ្ងៃ ។ ប្រសិនបើជាការប្រញាប់រយៈពេលនេះត្រូវបន្ថយមកត្រឹម ៨ថ្ងៃ ។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិកដែលប្រធានបានប្រគល់ភារកិច្ចឱ្យពិនិត្យរាយការណ៍ ។ ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ ក្នុងករណីដែលបែងចែកសំឡេងជាពីរស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាក្រុមប្រឹក្សាធម្មនុញ្ញជាសំឡេងឧត្តមានុភាព ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់ពីហេតុផល ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល និងចុះផ្សាយក្នុងរាជកិច្ច ។ ប្រធានរដ្ឋសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់ ។ នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងនេះទៅសមាជិករាជរដ្ឋាភិបាលទាំងអស់ ។ ប្រធានតុលាការកំពូលត្រូវជូនដំណឹងនេះទៅដល់តុលាការសាមី ។[40]

## ៣.២. សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាព ។ក្រុមប្រឹក្សាធម្មនុញ្ញក៏មានសមត្ថកិច្ចក្នុងការដោះស្រាយនៅវិវាទទាក់ទងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបោះឆ្នោតជ្រើសរើសព្រឹទ្ធសភា និងដោះស្រាយទៅលើវិវាទកម្មការបោះឆ្នោតផងដែរ ។

### ៣.២.១.សមត្ថកិច្ចដោះស្រាយវិវាទក្នុង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

យោងលើមាត្រា ២៥ ២៦ ២៧ ២៨ ២៩ ៣០ ៣១ ៣២ ៣៣ ៣៤ ៣៥ នៃច្បាប់ស្តីពីការ

---

([39]). មាត្រា២១ ច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

([40]) .មាត្រា២៤ ច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

រៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៨ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីសម្រេចដូចតទៅនេះ :

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។[41]

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេច ៖

១. លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយឬរបស់បេក្ខជនប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធលើការតវ៉ាពីបេក្ខភាព ឬសម្រេចបដិសេធលើការតវ៉ាពីបញ្ជីរាយនាមបេក្ខជន។ ការប្តឹងនេះត្រូវប្តឹងឡើងក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

២. លើបណ្តឹងតវ៉ារបស់បុគ្គលប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាសុំចុះឈ្មោះបោះឆ្នោត។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

៣. លើបណ្តឹងតវ៉ារបស់បុគ្គលឬអ្នកតំណាងប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធអំពីការបាត់ឈ្មោះ ឬអំពីការជំទាស់នឹងការចុះឈ្មោះ ឬអំពីការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនូវបុគ្គលណាម្នាក់ដែលគេយល់ឃើញថាមានលក្ខណៈមិនត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរក្រោយពីបានទទួលលិខិតជូនតំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីខាងលើក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

៤. លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយពីការមិនព្រមចុះបញ្ជីគណបក្សនយោបាយ បណ្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនតំណឹងរបស់ក្រសួងមហាផ្ទៃ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីនេះក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយ។[42]

([41]). មាត្រា២៥ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

([42]).មាត្រា២៦ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេច ៖

១. លើបណ្តឹងតវ៉ាដោយផ្ទាល់អំពីលទ្ធផលនៃការបោះឆ្នោតដែលបុគ្គលឬគណបក្សនយោបាយដែលបានឈរបោះឆ្នោតមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ។ បណ្តឹងត្រូវធ្វើឡើងក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរ បន្ទាប់ពីរការប្រកាសលទ្ធផលបណ្តោះអាសន្ន ។

២. លើបណ្តឹងតវ៉ារបស់បុគ្គលឬគណបក្សដែលមិនសុខចិត្តនឹងសើចក្តីសម្រេចរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ។ ការប្តឹងតវ៉ានេះត្រូវធ្វើឡើងក្នុងរយះពេល ៤៨ម៉ោងយ៉ាងយូរ ក្រោយពីទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីខាងលើក្នុងរយៈពេល ២០ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ។[43]

បុគ្គលណាឬគណបក្សនយោបាយណាដែលមិនសុខចិត្ត នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ត្រូវធ្វើពាក្យប្តឹងជាលាយលក្ខណ៍អក្សរជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ។ ពាក្យសុំនេះត្រូវបញ្ជាក់៖

១. ឈ្មោះបុគ្គល ឬឈ្មោះគណបក្សនយោបាយ ដែលជាអ្នកប្តឹងតវ៉ា

២. ឋានៈតាមផ្លូវច្បាប់របស់អ្នកប្តឹងតវ៉ា ( ជាអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬជាបេក្ខជន ឬជាតំណាងគណបក្សនយោបាយ )

៣. ឈ្មោះមណ្ឌលបោះឆ្នោតដែលមានការប្តឹងតវ៉ា

៤. ឈ្មោះបុគ្គល ឬគណបក្សនយោបាយដែលត្រូវបានគេប្រកាសថាជាប់ឆ្នោតហើយដែលគេប្តឹងតវ៉ា

៥. គ្រប់ឯកសារឬភស្តុតាងសម្រាប់គាំទ្រការសុំបដិសេធ។

ក្រុមបឹក្សាធម្មនុញ្ញអាចសម្រេចមិនធ្វើការស៊ើបអង្កេតលើបណ្តឹងណាមួយ បើបណ្តឹងនោះមិនបំពេញលក្ខខណ្ឌកំណត់ក្នុងមាត្រានេះ ។

គ្រប់ករណីទាំងអស់ដែលប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញមិនតម្រូវឲ្យបង់ប្រាក់ទេ ។[44]

ពាក្យប្តឹងតវ៉ាគ្មានអានុភាពត្រូវបានផ្អាកការអនុវត្តទេ ។ ប៉ុន្តែក្នុងពេលរងចាំសេចក្តីសម្រេចស្ថាពរក្រុមប្រឹក្សាធម្មនុញ្ញបើយល់ឃើញថាចាំបាច់ អាចចេញបញ្ជាជាបឋមមួយដើម្បីព្យួរជាប

(43).មាត្រា២៧ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

(44). មាត្រា២៨ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

ណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រណាម្នាក់ ឬគណបក្សនយោបាយណាមួយដែលគេប្តឹងតវ៉ាបាន ។ បញ្ហានេះនឹងត្រូវបញ្ចប់អានុភាពនៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចជាស្ថាពរ ។[45]

ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្រុមប្រឹក្សាធម្មនុញ្ញចែកចេញជា ៣ក្រុម។ ក្រុមនីមួយៗមានសមាជិក ៣រូប ដែល ១រូប ជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង ១រូបទៀតជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្នុងក្រុមទាំង ៣នេះត្រូវ ជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។[46]

ក្រោយពីបានទទួលពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវប្រគល់សិទ្ធិទៅឲ្យក្រុមណាមួយទទួលខុសត្រូវធ្វើការស៊ើបអង្កេត ។ ក្រុមនោះត្រូវជូនដំណឹងជាលាយលក្ខអក្សរជាបន្ទាន់ដល់អ្នកប្តឹងតវ៉ា និងដល់ជនឬគណបក្សដែលត្រូវគេប្តឹងតវ៉ាថា គេមានពេលយ៉ាងយូរ ១០ថ្ងៃ ដើម្បីពិនិត្យលើសេចក្តីប្តឹងតវ៉ានិងភស្តុតាង ដែលភាគីបានផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ និងដើម្បីរៀបចំលិខិតឆ្លើយតបជាលាយលក្ខអក្សរ ។[៤៧]

ក្រោយពីទទួលលិខិតឆ្លើយតបខាងលើនេះ ឬក្រោយផុតកំណត់យៈពេល ១០ថ្ងៃ និងក្រោយធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ហើយ ក្រុមដែលទទួលបន្ទុកត្រូវដាក់លទ្ធផលនៃការស៊ើបអង្កេតព្រមទាំងយោបល់របស់ក្រុមនេះ ជូនក្រុមប្រឹក្សាធម្មនុញ្ញពេញអង្គ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចឲ្យធ្វើការស៊ើបអង្កេតបន្ថែមទៀតហើយអាចស្តាប់អ្នកប្តឹងតវ៉ាដោយផ្ទាល់បាន ។[48]

ក្នុងពេលធ្វើការស៊ើបអង្កេត ក្រុមប្រឹក្សាធម្មនុញ្ញឬក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញអាចធ្វើការសាកសួរលើគ្រប់បញ្ហាទាំងអស់ ទារឯកសារនឹងរបាយការណ៍ផ្សេងៗនិងកោះអញ្ជើញជនទាំងឡាយដែលពាក់ព័ន្ធក្នុងការបោះឆ្នោត។

ក្រុមប្រឹក្សាធម្មនុញ្ញឬក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ អាចចាត់តាំងបុគ្គលិករបស់ខ្លួនឬបុគ្គលផ្សេងទៀតឲ្យជួយក្នុងការស៊ើបអង្កេត ជាពិសេសនៅពេលទទួលចម្លើយរបស់សាក្សីដែលបានធ្វើសច្ចាប្រណិធានហើយ ។ កំណត់ហេតុជាលាយលក្ខអក្សរនៃចម្លើយរបស់សាក្សីត្រូវតម្កល់ទុកសម្រាប់

([45]). មាត្រា២៩ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

([46]). មាត្រា៣០ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

([47]). មាត្រា៣១ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

([48]). មាត្រា៣២ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

ភាគីទាំងអស់ ។ បើអ្នកស៊ើបអង្កេតឬសមាជិកក្នុងក្រុមណាម្នាក់ដឹងថាសាក្សីមានការភ័យខ្លាចគេធ្វើបាបឈ្មោះសាក្សីនោះត្រូវរក្សាទុកជាសម្ងាត់មិនឲ្យនរណាដឹងទាំងអស់ក្រៅពីក្រុមប្រឹក្សាធម្មនុញ្ញ គឺឲ្យដឹងតែអំពីខ្លឹមសារនៃចម្លើយតែប៉ុណ្ណោះ ។[49]

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តីក្នុងករណីដែលមានការតវ៉ា អំពីនីយុតភាពនៃការបោះឆ្នោត អំពីភាពអាចជ្រើសតាំងបាននៃបេក្ខជនសម្រាប់បោះឆ្នោត និងភាពអាចជ្រើសតាំងបាននៃបេក្ខជនដែលប្រកាសថាជាប់ឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចយល់ស្របឬមិនយល់ស្របតាមសេចក្តីសម្រេចរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចប្រកាសមោឃភាពនៃការបោះឆ្នោតដែលគេប្តឹងតវ៉ាឬប្រកាសថាបេក្ខជនជាប់ឆ្នោតដោយត្រឹមត្រូវ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

សេចក្តីសម្រេចនេះត្រូវថ្វាយព្រះមហាក្សត្រ បញ្ជូនទៅរដ្ឋសភានិងរាជរដ្ឋាភិបាលហើយត្រូវចុះក្នុងរាជកិច្ច ។[50]

ក្រុមប្រឹក្សាមានសិទ្ធិបញ្ជូនបណ្តឹងដែល មិនមានចូលក្នុងសមត្ថកិច្ចរបស់ខ្លួនទៅអង្គការមានសមត្ថកិច្ច ។[51]

### ៣.២.២.សមត្ថកិច្ចដោះស្រាយវិវាទក្នុង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

យោងលើមាត្រា ២៥ថ្មី ២៧ថ្មី ២៩ថ្មី ៣០ថ្មី ៣៩ថ្មី នៃព្រះរាជក្រមស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែវិច្ឆការ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមរយៈសេចក្តីសម្រេចលេខ ០៩០/០០១/២០០៧ កមធ.ច ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ហើយបានសម្រេចទាំងស្រុងដូចតទៅនេះ :

(49). មាត្រា៣៣ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

(50). មាត្រា៣៤ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

(51). មាត្រា៣៥ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ១៩៩៨

ក្រុមប្រឹក្សាធម្មញ្ញមានសិទ្ធិពិនិត្យ និសម្រេចអំពីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។[52]

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេចៈ

**១**. លើបណ្តឹងតវ៉ាដោយផ្ទាល់ពីលទ្ធផលនៃការបោះឆ្នោត ដែលបុគ្គល ឬ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ។ បណ្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៧២ម៉ោង យ៉ាងយូរ បន្ទាប់ពីប្រកាសលទ្ធផលបណ្តោះអាសន្ន ។

**២**. លើបណ្តឹងតវ៉ារបស់បុគ្គល ឬ គណបក្សដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេដការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ។ ការប្តឹងតវ៉ានេះត្រូវធ្វើឡើងក្នុងរយៈពេល ៧២ម៉ោង យ៉ាងយូរក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើករណីខាងលើក្នុងរយៈពេល ២០ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលពាក្យបណ្តឹង ។[53]

ពាក្យបណ្តឹងតវ៉ាគ្មានអានុភាពផ្អាកការអនុវត្តទេ ។ ប៉ុន្តែក្នុងពេលរង់ចាំសេចក្តីសម្រេចស្ថាពរក្រុមប្រឹក្សាធម្មនុញ្ញ បើយល់ឃើញថាចាំបាច់ អាចចេញបញ្ជាបមមួយដើម្បីព្យួរជាបណ្តោះអាសន្ន នៃលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតាំងរាស្ត្រណាម្នាក់ ឬ សមាជិកព្រឹទ្ធសភាណាម្នាក់ ឬគណបក្សនយោបាយណាមួយដែលគេប្តឹងតវ៉ាបាន ។ បញ្ជានេះនឹងត្រូវបញ្ចប់អានុភាពនៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចជាស្ថាពរ ។[54]

ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសតាំងតាំងសមាជិកព្រឹទ្ធីសភា ក៏ដូចជាស្រាវជ្រាវត្រួតពិនិត្យធម្មនុញ្ញភាព ឬបកស្រាយច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញចែកចេញជា ៣ក្រុម ។ ក្រុមនីមួយៗមានសមាជិក ៣រូប ដែល ១រូបជាសាជិកតែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង ១រូបទៀតជា

(52). មាត្រា២៥ ថ្មី នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្នុងប្រឹក្សាធម្មនុញ្ញ

(53). មាត្រា២៧ ថ្មី នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្នុងប្រឹក្សាធម្មនុញ្ញ

(54). មាត្រា២៩ ថ្មី នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្នុងប្រឹក្សាធម្មនុញ្ញ

សមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្នុងក្រុមទាំង ៣ នេះ ត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។[55]

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តីក្នុងករណីដែលមានការតវ៉ាអំពីនីតិភាពនៃការបោះឆ្នោត អំពីភាពអាចជ្រើសតាំងបាននៃបេក្ខជនសម្រាប់បោះឆ្នោត នឹងភាពអាចជ្រើសតាំងបាននៃបេក្ខជនដែលត្រូវប្រកាសថាជាប់ឆ្នោត ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចយល់ស្រប ឬមិនយល់ស្របតាមសេក្តីសម្រេចរបស់គណកម្មាធការជាតិរៀបចំការបោះឆ្នោត អាចប្រកាសមោឃៈភាពនៃការបោះឆ្នោតដែលគេប្តឹងតវ៉ា ឬប្រកាសថាបេក្ខជនជាប់ឆ្នោតដោយត្រឹមត្រូវ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

សេចក្តីសម្រេចនេះត្រូវថ្វាយព្រះមហាក្សត្រ បញ្ជូនទៅព្រឹទ្ធសភា ឬរដ្ឋសភា និងរាជរដ្ឋាភិបាល ហើយចុះក្នុងរាជកិច្ច ៕[56]

(55). មាត្រា៣០ ថ្មី នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្នុងប្រឹក្សាធម្មនុញ្ញ

(56). មាត្រា៣៤ ថ្មី នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្នុងប្រឹក្សាធម្មនុញ្ញ

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានបកស្រាយលម្អិតអំពីរចនាសម្ព័ន្ធ អំពីខុទ្ទកាល័យ និងការបកស្រាយអំពីនាយកដ្ឋាន ការបកស្រាយអំពីការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ជាពិសេសបានបកស្រាយអំពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ដែលជាស្ថាប័នកំពូល និងយ៉ាងសំខាន់មួយនៅក្នុងព្រះរាជាណាចក្រកម្ពុជារួចមក ឃើញថាស្ថាប័នធម្មនុញ្ញ មួយនេះពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការធានា ការពារការគោរពរដ្ឋធម្មនុញ្ញ ពិនិត្យ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលជាច្បាប់កំពូលមិនឱ្យ អំណាចណាមួយរំលោភបំពានបានឡើយ ជាពិសេសសមត្ថកិច្ចសំខាន់មួយទៀតគឺ ដោះស្រាយនូវវិវាទកម្មដែលកើតចេញ ពីការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលជាកិច្ចការយ៉ាងសំខាន់មួយផ្នែកក្នុងការជួយពង្រឹងដល់លិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋនៅកម្ពុជាដែល មានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជារបស់យើងផងដែរ ។

ក្រោយពីចាប់ដំណើរការពេញលក្ខណៈនៅឆ្នាំ ១៩៩៨ រហូតមកដល់បច្ចុប្បន្នយើងនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានបំពេញនូវការងាររបស់ខ្លួនយ៉ាងច្រើន ដូចជា ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ការបកស្រាយរដ្ឋធម្មនុញ្ញ ការបកស្រាយច្បាប់ ការរៀបចំនូវរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាធម្មនុញ្ញឡើងវិញឱ្យបានកាន់តែប្រសើរ ជាពិសេសគឺបានរៀបចំនៅអគ្គនាយកដ្ឋាននីមួយៗបានយ៉ាងល្អប្រសើរ ហើយបានរៀបចំនៅវិន័យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់ឱ្យសមាជិកក្រុមប្រឹក្សាមានវិន័យនិងការគោរពនៅតួនាទីកាន់តែប្រសើរជាងមុនទៅទៀត មួយវិញទៀតក្រុមប្រឹក្សាធម្មនុញ្ញបានដោះស្រាយនៅបណ្តឹងដែលពាក់ព័ន្ធវិវាទនៅក្នុងការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាមរយៈសេចក្តីសម្រេចរបស់ខ្លួន ។ ទាំងនេះ សបញ្ជាក់យ៉ាងច្បាស់ថាក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នឯករាជ្យ និងមិនប្រកាន់ឥរិយាបទអព្យាក្រឹត្យភាព ដែលដាច់ចេញពីអំណាច ទាំងបីគឺដាច់ចេញពី អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចរបស់តុលាការ យ៉ាងពិតប្រាកដ ។

# ឯកសារយោង

# ឯកសារយោង

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ព្រះរាជក្រម នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រះរាជក្រម នស/រកម/០៤៩៨/០៥ ចុះថ្ងៃទី ០៨/០៤/៩៨ ប្រកាសឲ្យប្រើច្បាប់បន្ថែមទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ព្រះរាជក្រម ជស/រកម/០៣១៥/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃ
- ព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ មេសា ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលរដ្ឋសភាបានអនុម័តខែមីនា នាសម័យប្រជុំលើកទី០៨ នីតិកាលទី១
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ២០០៧
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ២០១៨
- ច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅក្នុងក្រុមប្រឹក្សាធម្មនុញ្ញ
- ច្បាប់ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៨៩ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ ដែលប្រកាសប្រើឯកសណ្ឋានក្នុងសវនាការជំនុះជម្រះ កិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិ៣ឆ្នាំលើកទី៧ (ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩)
- អនុក្រឹត្យស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ៩២ អនក្រ.បក ស្តីពី ការបង្កើតអគ្គលេខាធិការដ្ឋាន
- បទញ្ញាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញ
- បទបញ្ញា ស្តីពីនីតិវិធីដែលត្រូវអនុវត្ត នៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

- បទឧទ្ទេសនាមរបស់សម្តេច នរោត្តម សិរីវុឌ្ឍ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពី ខ្លឹមសាររដ្ឋធម្មនុញ្ញ និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- ឯកសារស្តីពី ការបង្កើតខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
- សេចក្តីសម្រេច ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ពាក្យបណ្តឹង សេចក្តីសម្រេច និងសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ៣ឆ្នាំ លើកទី៥
- សៀវភៅ ស្តីពីពិនិត្យធម្មនុញ្ញភាព
- កូនសៀវភៅ ក្រុមប្រឹក្សាធម្មនុញ្ញ
- ទស្សនាវដ្តី ក្រុមប្រឹក្សាធម្មនុញ្ញ
- សៀវភៅស "*ក្រុមប្រឹក្សាធម្មនុញ្ញ*" ២០១៨
- http://www.ccc.gov.kh/admin/uploads/CCC%20Law.pdf
- http://www.ccc.gov.kh/admin/uploads/u_regulars.pdf
- http://www.ccc.gov.kh/admin/uploads/u_regulation1.pdf
- http://www.ccc.gov.kh/admin/uploads/u_law_old.pdf

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ទំព័រ**

១.រូបថតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ........................................................................................................ ១

២.ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសឲ្យប្រើនៅ ថ្ងៃទី ០៨ ខែមេសាឆ្នាំ១៩៩៨ ................................................................................................................................ ៩

៣.ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ............២២

៤.ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៨៩ ស្តីពីឯកសណ្ឋានក្នុងសវនាការជំនុំជម្រះ ឬកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៨ ...................................៣០

៥.ព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ប្រកាសឲ្យច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា
ធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៩ ខែមីនា ឆ្នាំ ១៩៩៨ .................................៤០

៦.បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធិដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ(បោះពុម្ពផ្សាយដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ ២០០៣)......៤៨

៧.បទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ (លេខ ២៤ កបធ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ១៩៩៨)...................................................................................................................៥៧

៨.បទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ(សេចក្តីសម្រេចលេខ
០៥/ ៩៩ កមធ.ច.សស.រ ចុះថ្ងៃទី២១/០៥/៩៩) ......................................................................៦០

៩.សេចក្តីពីសម្រេចលេខ ១៩៣/០០១/២០១៨ កបធ.ច ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៨ .............៦៥

១០.បទឧទ្ទេសនាមរបស់សម្តេច នរោត្តម សិរីវុឌ្ឍ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីខ្លឹមសាររដ្ឋធម្មនុញ្ញនិងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (នៅគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១៣)................................................................................................................. ៧៣

១១.កម្រងឯកសារស្តីពីការបង្កើត ខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ......................................៨៥